KH/2010/CL/CON1/31
Phnom Penh, October 2010
Original: English

គន្លឹះ ១០

# គន្លឹះ ១០

សម្រាប់អនុសញ្ញាស្តីពី
ការការពារ និងការលើកស្ទួយ

# ភាពផ្សេងៗគ្នា
# នៃវិញ្ញត្តិវប្បធម៌

United Nations
Educational, Scientific and
Cultural Organization

ឯកសារនេះត្រូវបានផ្សព្វផ្សាយជាព័ត៌មាន មិនមានបំណងបកស្រាយ ឬបំពេ⊠
បន្ថែមទៅលើអនុសញ្ញាស្តីពីការការពារ ⊠⊠ ការលើកស្ទួយភាពផ្សេងៗគ្នានៃ
វិញ្ញត្តិវប្បធម៌ឡើយ (ឆ្នាំ២០០៥)

# គន្លឹះ១០

## សម្រាប់អនុសញ្ញាស្តីពី
## ការការពារ និងការលើកស្ទួយ

# ភាពផ្សេងៗគ្នា
# នៃវិញ្ញត្តិវប្បធម៌

អនុម័តដោយសម័យប្រជុំលើកទី៣៣នៃមហាសន្និបាតអង្គការយូណេស្កូ ឆ្នាំ២០០៥


១ ហេតុអ្វីបានជាត្រូវមានអនុសញ្ញា ? ........................................ 2
ដើម្បីរក្សាស្វាមីភក្តិចំពោះបេសកកម្មនៃអង្គការយូណេស្កូ
ដើម្បីដើរទន្ទឹមគ្នានឹងការវិវត្តនៃសញ្ញាណវប្បធម៌
ដើម្បីបំពេញសកម្មភាពនៃអង្គការយូណេស្កូ ប្រកបដោយអត្ថប្រយោជន៍ និងស្រប តាមនិយាមត្រឹមត្រូវ ក្នុងវិស័យវប្បធម៌

២ តើកម្មវត្ថុនៃអនុសញ្ញាមានអ្វីខ្លះ ?........................................... 4

៣ តើគោលបំណងច្បាស់លាស់នៃអនុសញ្ញាមានអ្វីខ្លះ ?............. 5

៤ តើគោលការណ៍តម្រង់ទិសនៃអនុសញ្ញាមានអ្វីខ្លះ ?................. 6

៥ តើសិទ្ធិនិងកាតព្វកិច្ចសម្រាប់ភាគីហត្ថលេខីនៃ អនុសញ្ញានីមួយៗ មានអ្វីខ្លះ ?........................................................................ 6
សិទ្ធិ
កាតព្វកិច្ច
ការគាំទ្រទៅវិញទៅមក ការបំពេញគ្នា និងភាពមិនចំណុះគ្នា

៦ តើអនុសញ្ញាចូលជាធរមាននៅពេលណា ?....................................... 9
ការផ្តល់សច្ចាប័ន
ការចូលជាធរមាន

៧ តើអនុសញ្ញាដំណើរការរបៀបដូចម្តេច ?........................................ 9
យន្តការតាមដាន
មធ្យោបាយ
ការដោះស្រាយទំនាស់

៨ តើនរណាខ្លះជាអ្នកធានាសំខាន់ៗនៃអនុសញ្ញា ?................................ 10

៩ តើនរណាខ្លះដែលអ្នកទទួលអត្ថប្រយោជន៍ពីអនុសញ្ញា?.................... 10

១០ តើគោលគំនិតសំខាន់ៗនៃអនុសញ្ញាមានអ្វីខ្លះ ?............................ 11

ឧបសម្ពន្ធ.............................................................................. 13
ឯកសារមួយចំនួនរបស់អង្គការយូណេស្កូ ទាក់ទងនឹងភាពផ្សេងៗគ្នានៃវប្បធម៌
ឯកសារស្តីពី ភាពផ្សេងៗគ្នានៃវប្បធម៌
ឯកសារទាក់ទងនឹងអនុសញ្ញា

# ១ ហេតុអ្វីបានជាត្រូវមានអនុសញ្ញា?

## ដើម្បីរក្សាស្វាមីភក្តិចំពោះបេសកកម្មនៃអង្គការយូណេស្កូ

អង្គការយូណេស្កូជាស្ថាប័នតែមួយគត់ដែលទទួលបន្ទុកផ្នែកវប្បធម៌ក្នុងចំណោមស្ថាប័នអង្គការសហប្រជាជាតិទាំងអស់។ សារលិខិតជាបតិដ្ឋាប័ននៃអង្គការ (1946) បានប្រគល់បេសកកម្មពីរអោយអង្គការនេះ ទីមួយគឺការលើកស្ទួយ "ភាពផ្សេងៗគ្នាដ៏សម្បូរបែប" និង "ការសម្រួលដល់ការផ្លាស់ប្តូរគំនិតគ្នាទៅវិញទៅមក តាមរយៈពាក្យសំដី និងរូបភាព"។

គោលការណ៍គ្រឹះទាំងនេះ រួមមានភាពផ្សេងៗគ្នា និងសេរីភាពនៃការយោគយល់គ្នា តែងតែស្ថិតនៅទន្ទឹមនឹងគ្នាជានិច្ច ស្របតាមគោលដៅដែលអង្គការយូណេស្កូកំណត់ឡើង ក្នុងការ "ប្រមូលផ្តុំវប្បធម៌នានា មិនមែនដើម្បីធ្វើឲ្យមានលក្ខណៈដូចៗគ្នានោះឡើយ តែឲ្យមានឯកលក្ខណភាព នៅខាងក្នុងភាពផ្សេងៗគ្នា ដើម្បីកុំឲ្យមនុស្សម្នាក់ៗនៅជិតជាប់នឹងវប្បធម៌របស់ខ្លួនខ្លាំងពេក តែឲ្យគេម្នាក់ៗទទួលអត្ថប្រយោជន៍ពីវប្បធម៌សាកល ដែលមានឯកលក្ខណៈផង និងមានលក្ខណៈទីទៃពីគ្នាផង"។ (របាយការណ៍របស់អគ្គនាយក ឆ្នាំ១៩៤៧)។

ការបន្តសកម្មភាពឲ្យស្របតាមគោលដៅនេះ មិនត្រឹមតែមានមូលដ្ឋានគ្រឹះលើការសង្កេតឃើញថាមានភាពផ្សេងៗគ្នានេះប៉ុណ្ណោះទេ តែថែមទាំងផ្អែកទៅលើលទ្ធភាពក្នុងការជជែកពិភាក្សាគ្នា ដែលយើងបើកឲ្យកាន់តែទូលាយជាងមុន។ ដូច្នេះ អង្គការយូណេស្កូបានលើកយកគោលដៅនេះធ្វើជាចំណុចស្នូលក្នុងបេសកកម្មរបស់ខ្លួន ហើយតែងតែលើកយកវិធីសាស្ត្រ និងសកម្មភាពទាំងនោះ មកអនុវត្តឡើងវិញឥតឈប់ឈរ។ ជាតឹកតាង យើងទទួលបាននូវការទទួលស្គាល់ភាពថ្លៃថ្នូរស្មើៗគ្នាចំពោះគ្រប់វប្បធម៌ទាំងអស់ ការការពារសម្បត្តិវប្បធម៌ ការលើកស្ទួយ ការពិភាក្សាអន្តរវប្បធម៌ ការគោរពសិទ្ធិវប្បធម៌ ការកំណត់គោលនយោបាយវប្បធម៌ដើម្បីភាពផ្សេងគ្នា ការលើកស្ទួយពហុភាពបែបស្ថាបនា ការអភិរក្សបេតិកភណ្ឌវប្បធម៌ ។ល។

ថ្វីត្បិតតែវប្បធម៌នៅតែជាគោលសំខាន់ដ៏ប្រសើរមួយនៃអង្គការយូណេស្កូ ក្នុងការកសាងសន្តិភាពទៅតាមស្មារតីមនុស្សជាតិក៏ពិតមែន ប៉ុន្តែការផ្លាស់ប្តូរខ្លាំងឡើងៗនៃបរិបទអន្តរជាតិ បានជំរុញឲ្យមានការវិវត្តផ្នែកវិធីសាស្ត្រទ្រឹស្តី កម្មវិធី និងបែបផែនសកម្មភាពរបស់អង្គការនេះ។

## ដើម្បីដើរទន្ទឹមគ្នានឹងការវិវត្តនៃសញ្ញាណវប្បធម៌

តាំងពីយូរយារមកហើយ វប្បធម៌ត្រូវបានគេចាត់ទុកថាស្ថិតនៅក្នុងផ្នែកវិចិត្រសិល្បៈ និងអក្សរសិល្ប៍ តែបច្ចុប្បន្ន វាស្ថិតនៅក្នុងដែនមួយដ៏ធំទូលាយជាងមុនយ៉ាងខ្លាំង ៖ "វប្បធម៌ត្រូវបានគេចាត់ទុកដូចជាបណ្តុំនៃលក្ខណៈសម្គាល់ខាង សាសនា សម្ភារៈ បញ្ញា និងសញ្ចេតនាដែលជាលក្ខណៈសម្គាល់នៃសង្គមមួយ ឬមនុស្សមួយក្រុម។ ក្រៅពីសិល្បៈ និងអក្សរសិល្ប៍ វារួមបញ្ចូលទាំងបែបផែននៃជីវិត របៀបរស់នៅជាមួយគ្នា ប្រព័ន្ធតម្លៃ ប្រពៃណី និងជំនឿ " (បុព្វកថានៃសេចក្តីប្រកាសជាសាកលនៃអង្គការយូណេស្កូស្តីពីភាពផ្សេងគ្នានៃវប្បធម៌ ឆ្នាំ២០០១)។

បើត្រឡប់ទៅអតីតកាលវិញ យើងអាចបែងចែកដំណាក់កាលសំខាន់ៗជាបួន ក្នុងការវិវត្តផ្នែកអត្ថន័យ និងមុខងារដែលគេលើកឡើងចំពោះវប្បធម៌។ វាជារឿងប្រាកដណាស់ដែលថា ដំណាក់កាលទាំងនោះមិនត្រូវបានបែងចែកដាច់ស្រឡះពីគ្នានោះឡើយ រីឯសកម្មភាពវិញត្រូវបានធ្វើឡើង ទៅតាមលំដាប់លំដោយដូចតទៅៈ

១- ពង្រីកបញ្ញត្តិវប្បធម៌ ពីបែបផលិតកម្មសិល្បៈ ឲ្យទៅជាបញ្ញត្តិនៃអត្តសញ្ញាណវប្បធម៌ (ទសវត្សទី៥០ និង៦០)។ ក្នុងកំឡុងពេលនោះ អង្គការយូណេស្កូបានការពារវប្បធម៌ដើម្បីឆ្លើយតបទៅនឹងស្ថានភាពផ្សេងៗពីគ្នា ដូចជាក្នុងសម័យបំបាត់របបអាណានិគម ដោយព្រមទទួលស្គាល់ថាត្រូវផ្តល់ភាពថ្លៃថ្នូរស្មើៗគ្នាដល់វប្បធម៌នានា។

២- ព្រមទទួលដឹងថាមានទំនាក់ទំនងសំខាន់ រវាងវប្បធម៌ និងការអភិវឌ្ឍន៍ ដែលបង្កើតឲ្យមានជាសហប្រតិបត្តិការអន្តរជាតិ និងសាមគ្គីភាពជាមួយនឹងប្រទេសកំពុងអភិវឌ្ឍ (ទសវត្សទី៧០ និង៨០)។ ក្នុងកំឡុងពេលនោះ អង្គការយូណេស្កូ មិនបោះបង់ចោលសកម្មភាពមុនៗរបស់ខ្លួនឡើយ ហើយចាប់ផ្តើមផ្តោតទៅលើកម្មវិធីទៅមក រវាងប្រទេសនានា និងសហគ្រាស ដើម្បីបើកផ្លូវឆ្ពោះទៅរកកិច្ចសហការជាដៃគូដែលផ្អែកទៅលើសមភាព។

៣- គិតគូរដល់បំណងប្រាថ្នា និងគ្រឹះវប្បធម៌ សម្រាប់ការកសាងលទ្ធិប្រជាធិបតេយ្យ (ទសវត្សទី៨០ និង៩០)។ ក្នុងកំឡុងពេលនោះ អង្គការយូណេស្កូ បានបង្ហាញពីចេតនាមិនចង់ឲ្យមានការរើសអើង និងការបោះបង់ចោលមនុស្សផងគ្នា ទៅលើជនរងគ្រោះមួយចំនួន ដូចជាជនភាគតិច អ្នកស្រុកជនជាតិដើម និងជនអន្តោប្រវេសន៍។

៤- លើកស្ទួយការពិភាក្សាវប្បធម៌ និងអរិយធម៌ជាមួយនឹងភាពផ្សេងៗគ្នាដ៏សម្បូរបែប ដែលត្រូវបានចាត់ទុកថាជាបេតិកភណ្ឌរួមគ្នានៃមនុស្សជាតិ តាមរយៈសេចក្តីប្រកាសជាសាកលនៃអង្គការយូណេស្កូស្តីពីភាពផ្សេងគ្នានៃវប្បធម៌ (ទសវត្សទី៩០ និង២០០០)។ ដើម្បីឆ្លើយតបទៅនឹងអត្ថន័យធំទូលាយនៃពាក្យវប្បធម៌ សេចក្តីប្រកាសនោះក៏បានលើកឡើងពីទិសដៅពីរ នៃភាពផ្សេងគ្នានៃវប្បធម៌ ៖ ទី១ ត្រូវធានាឲ្យបាននូវទំនាក់ទំនងស៊ីសង្វាក់គ្នា និងឆន្ទៈចង់រស់នៅរួមគ្នា រវាងមនុស្សនិងក្រុមមនុស្សដែលមានអត្តសញ្ញាណវប្បធម៌ច្រើន ប្លែកគ្នា និងរស់រវើក។ ទី២ ត្រូវការពារភាពផ្សេងគ្នាក្នុងការប្រឌិតគំនិតថ្មី មានដូចជាទម្រង់ចម្រុះនានា ដែលតាមរយៈទម្រង់ទាំងនោះ វប្បធម៌នានាស្តែងចេញជាលក្ខណៈបេតិកភណ្ឌ និងនវសម័យ ទៅតាមកាលនិងវេលា។ ក្នុងកំឡុងពេលនោះ អង្គការយូណេស្កូ ព្យាយាមឆ្លើយតបទៅនឹងតម្រូវការសង្គមដែលពហុលក្ខណៈរបស់វា រីកលូតលាស់ទៅតាមដំណើរការវិវត្តដ៏លឿននៃសាកលភាវូបនីយកម្ម។

ក្នុងនាមជាអភិក្រមបន្ត ប្រែប្រួល និងវិវត្តទៅមុខ វប្បធម៌តាក់តែងឡើងវិញនូវមត៌កវប្បធម៌ ទោះជាមានលក្ខណៈរូបីក្តី ឬអរូបីក្តី ទន្ទឹមនឹងនោះវាក៏បង្កើតឲ្យមានផងដែរនូវទម្រង់ថ្មីៗនៃការសម្តែង ដែលបង្ហាញឲ្យឃើញនូវភាពផ្សេងៗគ្នាជាអមតៈរបស់វា។ ក្នុងបរិបទអន្តរជាតិដែលផ្លាស់ប្តូរឥតឈប់ឈរ អង្គការយូណេស្កូតែងតែព្យាយាមនាំមកនូវចម្លើយជាក់ស្តែង ទៅនឹងបញ្ហាប្រឈមដែលកើតមានឡើងក្នុងសម័យកាលនីមួយៗ ទៅតាមអត្ថន័យនៃពាក្យវប្បធម៌ ដែលចេះតែវិវត្តទៅមុខ។ តាមរយៈឋាមពលជំរុញឲ្យមានការពិភាក្សាគ្នា និងគំនិតច្នៃប្រឌិត ភាពផ្សេងគ្នានៃវប្បធម៌គឺជាលក្ខខណ្ឌចាំបាច់នៃសន្តិភាព និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

## ដើម្បីបំពេញសកម្មភាពនៃអង្គការយូណេស្កូ ប្រកបដោយអត្ថប្រយោជន៍ និងស្របតាមនិយាមត្រឹមត្រូវ ក្នុងវិស័យវប្បធម៌

ចាប់តាំងពីពេលចាប់បដិសន្ធិមក ស្ថានភាពប្រឈមដែលកើតមានឥតឈប់ទាំងឡាយពាក់ព័ន្ធនឹងវប្បធម៌ បានជំរុញឲ្យកើតមានជាសកម្មភាពជាច្រើនបែបយ៉ាងច្រើនយ៉ាងនៅក្នុងអង្គការយូណេស្កូ រួមមាន ទីសិក្សាស្រាវជ្រាវគំនិតគ្រោងជាមុន និងកំណត់យុទ្ធសាស្ត្រ និងនយោបាយវប្បធម៌ឲ្យបានសមស្រប មណ្ឌលផ្លាស់ប្តូរព័ត៌មានដើម្បីប្រមូល បញ្ជូន ផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន ចំណេះដឹង និងការអនុវត្តល្អៗ ការរៀបចំអភិវឌ្ឍសមត្ថភាពមនុស្ស និងស្ថាប័ននៃរដ្ឋនានាដែលជាសមាជិក ការរៀបចំនិយាមដោយអញ្ជើញរដ្ឋដែលជាសមាជិកឲ្យព្រមព្រៀងគ្នាលើបទបញ្ញត្តិក្នុងរួម ក្នុងការពង្រឹងសហប្រតិបត្តិការអន្តរជាតិដ៏ពិតប្រាកដមួយ។

ក្នុងនាមជាអង្គការនិយាម អង្គការយូណេស្កូបានបង្កើតឧបករណ៍គតិយុត្តិអន្តរជាតិជាច្រើនជាលក្ខណៈកំហិត ស្តីពីវិស័យសំខាន់ៗទាំងបួននៃភាពផ្សេងគ្នាបែបច្នៃប្រឌិត ៖ បេតិកភណ្ឌវប្បធម៌ និងធម្មជាតិ សម្បត្តិវប្បធម៌សង្ហារិម បេតិកភណ្ឌវប្បធម៌អរូបី និងស្នាដៃប្រឌិតថ្មីក្នុងសម័យទំនើប។ សរុបទាំងអស់ អនុសញ្ញាចំនួន៧ ត្រូវបានតាក់តែងឡើង៖

- អនុសញ្ញាសាកលស្តីពីសិទ្ធិអ្នកនិពន្ធ (ឆ្នាំ១៩៥២ ប្រែសម្រួលឡើងវិញនៅឆ្នាំ ១៩៧១)
- អនុសញ្ញាស្តីពីការការពារសម្បត្តិវប្បធម៌ ក្នុងករណីមានជម្លោះប្រដាប់អាវុធ (ឆ្នាំ ១៩៥៤) (ពិធីសារទី១ ឆ្នាំ១៩៥៤, ពិធីសារទី២ ឆ្នាំ១៩៩៩ )
- អនុសញ្ញាទាក់ទងនឹងវិធានការដែលត្រូវចាត់ឡើងដើម្បីហាមឃាត់ និងទប់ស្កាត់កុំឲ្យមានការនាំចូល នាំចេញ និងផ្ទេរកម្មសិទ្ធិមិនស្របច្បាប់នៃសម្បត្តិវប្បធម៌ (ឆ្នាំ ១៩៧០)
- អនុសញ្ញាទាក់ទងនឹងការការពារបេតិកភណ្ឌពិភពលោក វប្បធម៌ និងធម្មជាតិ (ឆ្នាំ ១៩៧២)
- អនុសញ្ញាស្តីពីការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក (ឆ្នាំ២០០១)
- អនុសញ្ញាស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី (ឆ្នាំ២០០៣)
- អនុសញ្ញាស្តីពីការការពារ និងលើកស្ទួយភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ (ឆ្នាំ ២០០៥)

អនុសញ្ញាស្តីពីការការពារ និងលើកស្ទួយភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ ខុសប្លែកពីអនុសញ្ញានានាទាក់ទងនឹងបេតិកភណ្ឌ ពីព្រោះ ដំបូងបង្អស់ អនុសញ្ញានេះគិតទៅដល់ភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ ដូចដែលគេមានដាក់ឲ្យចរាចរណ៍ និងចែករំលែកដោយសកម្មភាពនានា គឺសម្បត្តិនិងសេវាកម្មវប្បធម៌ ដែលជាកត្តាសម័យទំនើបដ៏សំខាន់ ដ៏ប្រសើរនៃវប្បធម៌។

អនុសញ្ញានេះបំពេញបន្ថែមប្រកបដោយអត្ថប្រយោជន៍ ទៅលើវិធានគតិយុត្តិដែលអង្គការយូណេស្កូអនុវត្ត ដើម្បីជាប្រយោជន៍ដល់ភាពផ្សេងគ្នាបែបច្នៃប្រឌិត និងដើម្បីសម្រួលដល់បរិស្ថានពិភពលោក ដែលការប្រឌិតនៃបុគ្គលម្នាក់ៗ និងប្រជាជននានាត្រូវបានការពារទៅតាមភាពខុសគ្នាប្រកបដោយភាពសម្បូរបែបរបស់វា។

# ២ តើកម្មវត្ថុនៃអនុសញ្ញាមានអ្វីខ្លះ?

អនុសញ្ញាស្តីពីការការពារ និងលើកស្ទួយភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌មិនទាក់ទងទៅនឹងរាល់ទិដ្ឋភាពនៃភាពផ្សេងគ្នានៃវប្បធម៌ឡើយ គឺដូចមានចែងនៅក្នុងសេចក្តីប្រកាសជាសាកលរបស់អង្គការយូណេស្កូ ស្តីពីវិញ្ញត្តិវប្បធម៌។ អនុសញ្ញានេះសំដៅ ទៅលើដែនប្រធានបទច្បាស់លាស់មួយចំនួន ដូចមានចែងពីមាត្រាទី៨ ដល់ទី១១ រួមមាន ខ១ ភាពចាំបាច់ក្នុងការទទួលស្គាល់ថាសម្បត្តិ និងសេវាកម្មវប្បធម៌សុទ្ធតែជាសារធាតុទ្រទ្រង់អត្តសញ្ញាណ គុណធម៌ និងអត្ថន័យ ហើយមិនអាចចាត់ទុកជាទំនិញ ឬជាសម្បត្តិដែលត្រូវយកទៅប្រើប្រាស់ឲ្យដូចជាអ្វី ផ្សេងទៀតឡើយ។ ខ២ ភាពចាំបាច់សម្រាប់រដ្ឋនានាក្នុងការចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ហើយក្នុងពេលជាមួយគ្នានោះត្រូវធានាឲ្យបាននូវការផ្សព្វផ្សាយគំនិតនិងស្នាដៃ។ ខ៣ ភាពចាំបាច់ក្នុងការកំណត់ឡើងវិញនូវកិច្ចសហប្រតិបត្តិការអន្តរជាតិដែលជាចំណុចសំខាន់នៃអនុសញ្ញា ពីព្រោះទម្រង់ច្នៃប្រឌិតនីមួយៗសុទ្ធតែជាពន្លកនៃការសន្ទនាគ្នាជាអចិន្ត្រៃយ៍។

វត្ថុបំណងនៃអនុសញ្ញាគឺធ្វើឲ្យវិញ្ញត្តិវប្បធម៌មានទម្រង់ច្រើនខុសៗគ្នា។ វិញ្ញត្តិវប្បធម៌ទាំងនោះកើតចេញពីគំនិតច្នៃប្រឌិតរបស់បុគ្គល ក្រុម និងសង្គម ជាមួយនឹងខ្លឹមសារវប្បធម៌ដែលផ្សារភ្ជាប់ទៅនឹងអត្ថន័យជានិមិត្តរូប លក្ខណៈសម្បត្តិសិល្បៈ និងទៅលើតម្លៃវប្បធម៌ ដោយមានអត្តសញ្ញាណវប្បធម៌ជាប្រភពដើម ហើយសម្តែងចេញនូវអត្តសញ្ញាណវប្បធម៌នោះឡើង។ ទោះបីជាឧបករណ៍ និងបច្ចេកវិទ្យាដែលយកមកប្រើប្រាស់មានលក្ខណៈបែបណាក៏ដោយ ក៏គេត្រូវផ្ទេរចំណេះដឹងនៃវិញ្ញត្តិវប្បធម៌ទាំងនេះ

តាមរយៈសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ដែរ។ អនុសញ្ញាបានទទួលស្គាល់លក្ខណៈទ្វេនៃវិញ្ញត្តិវប្បធម៌ គឺលក្ខណៈសេដ្ឋកិច្ច និងវប្បធម៌ ហេតុដូចនេះហើយទើបគេមិនចាត់វាដូចជារបស់ធម្មតាសម្រាប់ការចរចាក្នុងគោលដៅពាណិជ្ជកម្មនោះឡើយ។

ទិសដៅទីមួយនៃអនុសញ្ញាគឺពង្រឹងកងទាំង៥ក្នុងច្រវាក់តែមួយដែលមិនអាចផ្ដាច់ចេញពីគ្នាបាន រួមមានការបង្កើតថ្មី ផលិតកម្ម ការចែកចាយ/ផ្សព្វផ្សាយ សិទ្ធិទទួលបាន និងការទទួលបានអត្ថប្រយោជន៍ពីវិញ្ញត្តិវប្បធម៌ ដែលធ្វើឡើងតាមរយៈសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។

តាមរយៈការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ អនុសញ្ញាបានកត់សំគាល់ឃើញថា ក្នុងពិភពដែលមានទំនាក់ទំនងគ្នាកាន់តែជិតស្និទ្ធឡើងបែបនេះ បុគ្គលម្នាក់ៗមានលទ្ធភាពកាន់តែទូលាយ និងឆាប់រហ័សឡើងក្នុងការទទួលបានវិញ្ញត្តិវប្បធម៌ដ៏សម្បូរបែប ដែលកើតឡើងនៅក្នុង ឬក្រៅប្រទេស តែអនុសញ្ញាបានសង្កេតឃើញផងដែរថានៅក្នុងបរិបទពិភពលោកនាពេលបច្ចុប្បន្ន លទ្ធភាពពុំទាន់មានពេញលេញនៅឡើយ។

គេត្រូវបញ្ជាក់ឲ្យបានច្បាស់ថា នៅក្នុងវាក្យសព្ទដែលអង្គការយូណេស្កូប្រើប្រាស់ពាក្យថា "ការពារ" មានន័យថាគឺជាការអនុម័តយកវិធានការសំដៅអភិរក្ស ថែរក្សា និងលើកតម្កើង។ គឺនៅក្នុងន័យនោះហើយដែល ពាក្យនេះត្រូវបានយកទៅប្រើប្រាស់ នៅក្នុងលិខិតូបករណ៍ផ្សេងៗ ដូចជាអនុសញ្ញាការពារបេតិកភណ្ឌពិភពលោក វប្បធម៌ និងធម្មជាតិ (ឆ្នាំ១៩៧២) អនុសញ្ញាស្ដីពីការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក (ឆ្នាំ២០០១) អនុសញ្ញាស្ដីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី (ឆ្នាំ២០០៣)។ នៅ ក្នុងបរិបទនេះ ពាក្យថា "ការពារ" ពុំមានន័យធៀបដូចជាពាក្យពេចន៍ប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្មនោះឡើយ។ ប្រើជាមួយនឹងពាក្យ "លើកស្ទួយ" ពាក្យនេះមានន័យថា គេចាំបាច់ត្រូវរក្សាឲ្យបានគង់វង្សនូវវិញ្ញត្តិវប្បធម៌ ដែលត្រូវបំផ្លាញដោយដំណើរការដ៏ឆាប់រហ័សនៃសាកលភាវូបនីយកម្ម។ ចំណែកឯពាក្យ "លើកស្ទួយ" វិញសំដៅបង្កើតឡើងវិញជានិរន្តនូវវិញ្ញត្តិវប្បធម៌ ដើម្បីប្រឆាំងនឹងសកម្មភាពសារមន្ទីរភាវូបនីយកម្ម ប្រពៃណីភាវូបនីយកម្ម ឬវត្ថុភាវូបនីយកម្ម។ ម៉្យាងទៀត ពាក្យទាំងពីរនេះ "ការពារ និងលើកស្ទួយ" មិនអាចផ្ដាច់ពីគ្នាបានឡើយ ព្រោះថាមាត្រា៧ ចែងពីការលើកស្ទួយ រីឯមាត្រា៨វិញ ចែងពីការការពារ។ ពាក្យថា "ការពារ " ដែលជួយស្រោចស្រង់ពាក្យ "លើកស្ទួយ" តែងតែជួយរំលឹកថា រាល់វិធានការដែលចាត់ចែងឡើងក្នុងទិសដៅនេះ ត្រូវតែ "អនុលោមទៅតាមបទបញ្ញត្តិនៃអនុសញ្ញានេះ" គឺត្រូវតែគោរពសិទ្ធិមនុស្ស សិទ្ធិសេរីភាពមូលដ្ឋាន និងកតិកាសញ្ញាអន្តរជាតិ។

## ៣ តើគោលបំណងច្បាស់លាស់នៃអនុសញ្ញាមានអ្វីខ្លះ?

តាមរយៈគោលដៅចម្បង គឺការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ គោលបំណងទូទៅនៃអនុសញ្ញាគឺសំដៅបង្កើតបរិស្ថានសមស្របមួយ ដែលអាចជំរុញឲ្យភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ត្រូវបានសំដែងឡើង ធ្វើឡើងជាថ្មី និងអាចផ្ដល់អត្ថប្រយោជន៍ដល់មនុស្សទាំងអស់ក្នុងសង្គម។ ធ្វើបែបនេះ វាពង្រឹងជាថ្មីនូវទំនាក់ទំនងដែលផ្សារភ្ជាប់វប្បធម៌ ការអភិវឌ្ឍ និងកិច្ចសន្ទនា ហើយអនុវត្តនូវបណ្ដុំគោលការណ៍ថ្មីមួយនៃកិច្ចសហប្រតិបត្តិការវប្បធម៌អន្តរជាតិ។ ដើម្បីសម្រេចគោលដៅនោះ អនុសញ្ញាមានបំណងជាពិសេសគឺចង់:

- បង្កើតលក្ខខណ្ឌនានាដែលអាចឲ្យវប្បធម៌រីកសុសសាយ និងមានទំនាក់ទំនងនឹងគ្នាដោយសេរី ធ្វើយ៉ាងណាឲ្យមានការបំពេញភាពសម្បូរបែប ឲ្យគ្នាទៅវិញទៅមក។
- ទទួលស្គាល់ពីលក្ខណៈពិសេសនៃសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ក្នុងនាមជាអ្នករក្សាអត្តសញ្ញាណ គុណធម៌ និងអត្ថន័យ។

- កំណត់ឡើងវិញនូវបែបបទថ្មីនៃសហប្រតិបត្តិការអន្តរជាតិ ដែលជាចំណុចសំខាន់នៃអនុសញ្ញា។
- អះអាងជាថ្មីនូវសិទ្ធិជាអធិបតេយ្យនៃរដ្ឋនានាក្នុងការរក្សា អនុម័ត និងអនុវត្តនយោបាយ និងវិធានការដែលរដ្ឋនីមួយៗវិនិច្ឆ័យថាសមរម្យ ដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ នៅលើទឹកដីរបស់ខ្លួន ព្រមទាំងធានាឲ្យបាននូវការផ្សព្វផ្សាយដោយសេរីនូវគំនិត និងស្នាដៃ។

គោលដៅចុងក្រោយនេះ ដែលកម្រិតដែនកំណត់នៃការអនុវត្តអនុសញ្ញា ចូលរួមក្នុងការបញ្ចូលការការពារភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ ទៅក្នុងអភិក្រមដែលមានលក្ខណៈចម្រុះមួយនៃសាកលភាវូបនីយកម្ម តែមិនមែនក្នុងអភិក្រមសេដ្ឋកិច្ចសុទ្ធសាធនោះឡើយ។

ដូច្នេះ ជាលើកទី១ហើយនៅក្នុងប្រវត្តិសាស្ត្រនៃច្បាប់អន្តរជាតិ ដែលវប្បធម៌ទទួលបាននូវមុខនាទីមួយដ៏ពិតប្រាកដនៅលើទិនានុលេខន៍នយោបាយ ក្នុងគោលបំណងចង់ជំរុញសាកលភាវូបនីយកម្មបម្រើឲ្យមនុស្សជាតិ។ នៅក្នុងន័យប្រវត្តិសាស្ត្រនេះ វប្បធម៌ក្លាយទៅជាបណ្តុំគោលការណ៍ដ៏ ពិតប្រាកដមួយនៃការពិភាក្សាគ្នា និងអភិវឌ្ឍន៍ ហើយក៏បើកទ្វារ ទៅរកដែនដីថ្មីនៃសាមគ្គីភាពផងដែរ។

## ៤ តើគោលការណ៍តម្រង់ទិសនៃអនុសញ្ញាមានអ្វីខ្លះ?

គោលការណ៍មួយចំនួនរំលឹក និងធានាថារាល់នយោបាយ និងវិធានការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌មិនត្រូវផ្ទុយទៅនឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានឡើយ ដូចជាសេរីភាពក្នុងការសំដែងមតិ ព័ត៌មាន និងទំនាក់ទំនងព្រមទាំងលទ្ធភាពនៃបុគ្គលទាំងឡាយក្នុងការជ្រើសរើសវិញ្ញត្តិវប្បធម៌។

លើសពីនោះ គោលការណ៍បើកទូលាយ និងគោលការណ៍លំនឹងធានាឲ្យរដ្ឋទាំងឡាយអនុម័តយកវិធានការទាំងឡាយ ដើម្បីសម្រួលដល់ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។ រដ្ឋទាំងនោះត្រូវធ្វើយ៉ាងណាលើកស្ទួយឲ្យបានសមស្រប នូវការបើកទូលាយទៅកាន់វប្បធម៌ផ្សេងទៀតនៅក្នុងពិភពលោក។

នៅក្នុងចំណោមគោលការណ៍ផ្សេងទៀតទាំងនោះ ក៏មានគោលការណ៍បំពេញបន្ថែមគ្នាផងដែរ ចំពោះទិដ្ឋភាពសេដ្ឋកិច្ច និងវប្បធម៌នៃការអភិវឌ្ឍ ព្រមទាំងការទិដ្ឋភាពនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលអនុសញ្ញាផ្តល់សារសំខាន់ជាខ្លាំង។

ចុងក្រោយ គោលការណ៍នៃសិទ្ធិទទួលបានប្រកបដោយសមភាពចែកជាពីរផ្នែក: សិទ្ធិទទួលបានវិញ្ញត្តិសម្បូរបែបនិងប្លែកៗគ្នា និងសិទ្ធិទទួលបានវិញ្ញត្តិនៃគ្រប់វប្បធម៌ទាំងអស់ តាមរយៈការសម្តែង និងការផ្សព្វផ្សាយសមស្រប។

## ៥ តើសិទ្ធិនិងកាតព្វកិច្ចសម្រាប់ភាគីហត្ថលេខីនៃអនុសញ្ញានីមួយៗមានអ្វីខ្លះ?

គោលដៅមួយក្នុងចំណោមគោលដៅចម្បងនៃអនុសញ្ញា គឺ "អះអាងជាថ្មីនូវសិទ្ធិជាអធិបតេយ្យនៃរដ្ឋទាំងឡាយក្នុងការអភិរក្ស អនុម័ត និងអនុវត្តគោលនយោបាយនិងវិធានការដែលរដ្ឋទាំងនោះវិនិច្ឆ័យថាសមរម្យ ដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌នៅលើដែនដីរបស់រដ្ឋទាំងអស់ "។ សេចក្តីអះអាងឡើងវិញលើសិទ្ធិនោះ មិនមែនសំដៅលើការបង្កើតផ្តាច់មុខរបស់រដ្ឋណាមួយនោះទេ តែវាជាការអនុវត្តន៍នូវកិច្ចដឹកនាំវប្បធម៌ គឺទំនាក់ទំនងរវាងអ្នកបំពេញសកម្មភាពជាលក្ខណៈបុគ្គល និងស្ថាប័ន ដែលចែករំលែកការទទួលខុសត្រូវទៅលើភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។

អនុសញ្ញាគូសបញ្ជាក់ចំពោះរដ្ឋភាគីទាំងអស់នូវសិទ្ធិ និងកាតព្វកិច្ចមួយចំនួន សំដៅការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ហើយទាំងអស់នោះត្រូវធ្វើឡើងក្នុងស្មារតីពង្រឹងគ្នាទៅវិញទៅមក និងបំពេញគ្នាជាមួយនឹងកតិកាសញ្ញាអន្តរជាតិដទៃទៀត និងត្រូវដឹកនាំទៅតាមការព្រមព្រៀងគ្នា និងសហប្រតិបត្តិការអន្តរជាតិ។

## សិទ្ធិ

ការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៃបុគ្គលម្នាក់ៗ គឺជាមូលដ្ឋានដ៏សំខាន់នៃអនុសញ្ញា។ ស្របតាមបន្ទាត់គោលការណ៍នៃសេចក្ដីប្រកាសជាសាកលរបស់អង្គការយូណេស្កូ ស្ដីពីភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ អនុសញ្ញាទទួលស្គាល់ថាមានការផ្សារភ្ជាប់គ្នារវាងភាពផ្សេងៗគ្នានៃវប្បធម៌ និងសមិទ្ធផលដ៏ពេញលេញនៃសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ពុំអាចមានចំណុចមួយ គ្មានចំណុចមួយទៀតបានឡើយ។ ក្នុងន័យនេះ "គ្មាននរណាម្នាក់អាចយកបទបញ្ញត្តិនៃអនុសញ្ញានេះ ទៅធ្វើឲ្យប៉ះពាល់ដល់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដូចបានចែងដោយសេចក្ដីប្រកាសជាសាកលនៃសិទ្ធិមនុស្ស ឬបានធានាអះអាងដោយសិទ្ធិអន្តរជាតិ ឬយកបទបញ្ញត្តិនេះទៅកាត់បន្ថយសិទ្ធិទាំងនោះបានឡើយ" ។ ដូច្នេះ ហានិភ័យនៃគោលការណ៍ទំនាក់ទំនងវប្បធម៌ដែល ក្នុងនាមភាពផ្សេងគ្នា ទទួលស្គាល់នូវការប្រតិបត្តិវប្បធម៌ផ្ទុយទៅនឹងគោលការណ៍មូលដ្ឋាននៃសិទ្ធិមនុស្ស ត្រូវបានគេបោះបង់ចោល។

អនុសញ្ញាអាចឲ្យរដ្ឋភាគីស្ទាបស្ទង់មើលពីវត្តមានស្ថានភាពពិសេសផ្សេងៗ ដែលវិញ្ញត្តិវប្បធម៌នៅលើទឹកដីស្ថិតនៅក្នុងហានិភ័យនៃការបាត់បង់ ប្រឈមមុខនឹងការគំរាម ឬក៏ត្រូវការការអភិរក្សជាបន្ទាន់តាមរូបភាពណាមួយ។ អនុសញ្ញាក៏អាចចាត់វាល់វិធានការសមស្របផងដែរ ដើម្បីការពារនិងរក្សាវិញ្ញត្តិវប្បធម៌ នៅក្នុងស្ថានភាពដូចបង្ហាញជូនខាងលើ។

ម៉្យាងទៀត អនុសញ្ញាទទួលស្គាល់សិទ្ធិជាអធិបតេយ្យនៃរដ្ឋភាគី ក្នុងការគាក់តែង និងអនុវត្តនយោបាយវប្បធម៌ និងក្នុងការអនុម័តវិធានការដើម្បីៈ

- អាចឲ្យសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ជាតិមានមុខនាទីរបស់ខ្លួន ក្នុងចំណោមសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ដែលមាននៅលើទឹកដីនៃរដ្ឋទាំងនោះ។
- ផ្គត់ផ្គង់ដល់ឧស្សាហកម្មវប្បធម៌ជាតិឯករាជ្យ និងដល់សកម្មភាពនៃវិស័យមិនផ្លូវការ ឲ្យមានលទ្ធភាពប្រើប្រើប្រាស់មធ្យោបាយផលិតកម្ម ផ្សព្វផ្សាយ និងចែកចាយសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌។
- លើកទឹកចិត្តដល់អង្គការដែលធ្វើការដោយគោលបំណងមិនរកប្រាក់ចំណេញ ព្រមទាំងស្ថាប័នរដ្ឋ និងឯកជន សិល្បករ និងអ្នកមានវិជ្ជាជីវៈក្នុងវិស័យវប្បធម៌ដទៃទៀត ក្នុងការអភិវឌ្ឍន៍ និងលើកស្ទួយនូវការផ្លាស់ប្ដូរគំនិតដោយសេរី និងការផ្សព្វផ្សាយដោយសេរីនូវគំនិត និងវិញ្ញត្តិវប្បធម៌ ព្រមទាំងសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌។
- លើកស្ទួយភាពផ្សេងៗគ្នានៃប្រព័ន្ធផ្សព្វផ្សាយ រួមទាំងការប្រើប្រាស់មធ្យោបាយសេវាកម្មសាធារណៈនៃការផ្សព្វផ្សាយតាមវិទ្យុ។
- ផ្ដល់ជំនួយហិរញ្ញប្បទានសាធារណៈ ព្រមទាំងបង្កើតនិងគាំទ្រស្ថាប័នសេវាកម្មសាធារណៈឲ្យបានសមស្រប។

## កាតព្វកិច្ច

ជាថ្នូរនឹងសិទ្ធិទាំងនេះ អនុសញ្ញាក៏បានគ្រោងទុកនូវកាតព្វកិច្ចជាច្រើនសម្រាប់រដ្ឋភាគី។ នៅក្នុងបណ្ដាកាតព្វកិច្ចទាំងនោះ អនុសញ្ញាអំពាវនាវឲ្យរដ្ឋភាគីៈ

- ខិតខំលើកស្ទួយនៅលើដីនៃដីរបស់ខ្លួននូវការបង្កើតឲ្យមានការលើកទឹកចិត្តបុគ្គល និងក្រុមមនុស្សក្នុងសង្គមឲ្យបង្កើត ផលិត ផ្សព្វផ្សាយ និងចែងចែកវិញ្ញត្តិវប្បធម៌ និងអាចទទួលបានវិញ្ញត្តិវប្បធម៌ទាំងនោះ ដោយគិតដល់លក្ខខណ្ឌនិងតម្រូវការពិសេសនៃស្ត្រី ព្រមទាំងក្រុមមនុស្សក្នុងសង្គម រួមទាំងមនុស្សដែលស្ថិតក្នុងចំណោមប្រជាជនភាគតិច និងជនជាតិដើម។ ម្យ៉ាងទៀត ត្រូវលើកទឹកចិត្តឲ្យទទួលបាននូវវិញ្ញត្តិវប្បធម៌ផ្សេងៗគ្នានៅលើទឹកដីរបស់ខ្លួន និងនៅក្នុងប្រទេសផ្សេងទៀតក្នុងពិភពលោក។
- ធ្វើយ៉ាងណាឲ្យមានការចែករំលែក និងមានតម្លាភាព ដោយផ្តល់ជូនបួនឆ្នាំម្តង ក្នុងរបាយការណ៍ដែលត្រូវប្រគល់ជូនទៅអង្គការយូណេស្កូ នូវព័ត៌មានសមស្រប ស្តីពីការចាត់វិធានការដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។
- ពន្យល់ដល់សាធារណជនអំពីសារៈសំខាន់នៃភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ តាមរយៈកម្មវិធីអប់រំ និងកម្មវិធីចលនាផ្សេងៗ។
- ទទួលស្គាល់នូវតួនាទីដ៏សំខាន់នៃសង្គមស៊ីវិលក្នុងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដោយលើកទឹកចិត្តឲ្យមានការចូលរួមយ៉ាងសកម្មនៃសង្គមស៊ីវិល រួមជាមួយនឹងរដ្ឋភាគី ដើម្បីសម្រេចគោលដៅនៃអនុសញ្ញា។
- បញ្ចូលវប្បធម៌ទៅក្នុងការអភិវឌ្ឍន៍ជានិរន្តរភាព និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីជាប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍ តាមរយៈមធ្យោបាយជាច្រើន ជាឧទាហរណ៍ ពង្រឹងឧស្សាហកម្មវប្បធម៌នៃប្រទេសទាំងនោះ ពង្រឹងសមត្ថភាពនៃប្រទេសទាំងនោះក្នុងការបង្កើត និងអនុវត្តនយោបាយវប្បធម៌ ផ្ទេរចំណេះដឹងផ្នែកបច្ចេកវិទ្យា ជួយឧបត្ថម្ភផ្នែកហិរញ្ញប្បទាន និងយកចិត្តទុកដាក់ជាពិសេសដល់សិល្បករ និងអ្នកមានវិជ្ជាជីវៈវប្បធម៌ដទៃទៀត ព្រមទាំងទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌។

## ការគាំទ្រទៅវិញទៅមក ការបំពេញគ្នា និងភាពមិនចំណុះគ្នា

រដ្ឋភាគីនៃអនុសញ្ញាមានសិទ្ធិ និងកាតព្វកិច្ចទាំងនេះ ក្នុងស្មារតីគាំទ្រគ្នា បំពេញគ្នាទៅវិញទៅមក និងមិនចំណុះទៅនឹងលិខិតុបករណ៍អន្តរជាតិដទៃទៀត។

ការអនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញា អាចបង្ហាញឲ្យឃើញនូវទំនាក់ទំនាក់គ្នារវាងសិទ្ធិ និងកាតព្វកិច្ចនៃរដ្ឋភាគីផ្សេងៗនៅក្នុងកតិកាសញ្ញាថ្មីនេះ ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចដែលមានប្រភពមកពីកិច្ចសន្យាអន្តរជាតិដទៃទៀត។ ការបង្កើនកិច្ចព្រមព្រៀងអន្តរជាតិ ធ្វើឲ្យការបញ្ចូលខសំខាន់បែបនេះនៃទំនាក់ទំនងរវាងកតិកាសញ្ញាកាន់តែមានសារប្រយោជន៍ឡើង ដើម្បីគ្រោងទុកជាមុនថាគួរតែធ្វើបទបញ្ញាដែលចេញមកពីលិខិតុបករណ៍ផ្សេងៗនោះតាមរបៀបណាខ្លះ និងបញ្ជាក់ឲ្យបានច្បាស់ពីលក្ខន្តិកៈគតិយុត្តិនៃអនុសញ្ញាមួយដោយប្រៀបធៀបទៅនឹងកតិកាសញ្ញាដទៃទៀត។

ដូច្នេះ ខសំខាន់មួយនៃទំនាក់ទំនងរវាងកិច្ចព្រមព្រៀងអន្តរជាតិ មានតួនាទីបញ្ជាក់ឲ្យបានច្បាស់ពីទំនាក់ទំនងរវាងកតិកាសញ្ញាទាំងនោះ ក្នុងករណីដែលមានភាពច្រំដែលនូវសិទ្ធិ ឬកាតព្វកិច្ចដែលចេញពីប្រភពមួយច្បាស់លាស់។ ក្នុងន័យនេះ អនុសញ្ញាគូសបញ្ជាក់ថារដ្ឋភាគីត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដោយស្មោះស្ម័គ្រ ចំពោះមុខអនុសញ្ញានេះ ព្រមទាំងអនុសញ្ញានានានៃរាល់កតិកាសញ្ញាផ្សេងទៀត ដែលរដ្ឋទាំងនោះជាសមាជិក ដោយមិនដាក់អនុសញ្ញានេះ នៅក្រោមចំណុះកតិកាសញ្ញាដទៃទៀតឡើយ។ ក្នុងគោលដៅនេះ រដ្ឋភាគីត្រូវជំរុញឲ្យមានគាំទ្រគ្នារវាងអនុសញ្ញានេះ និងកតិកាសញ្ញាដទៃទៀត ដែលរដ្ឋទាំងនោះជាសមាជិក ហើយរាប់បញ្ចូលបទបញ្ញត្តិដែលសមស្របនៃអនុសញ្ញានេះ នៅពេលដែលវាបកស្រាយ ឬអនុវត្តកតិកាសញ្ញាដទៃទៀតដែលខ្លួនជាសមាជិក ឬនៅពេលដែលរដ្ឋភាគីចុះឈ្មោះបំពេញកាតព្វកិច្ចអន្តរជាតិដទៃទៀត។ ទោះក្នុងករណីណាមួយក៏ដោយ អនុសញ្ញានេះបញ្ជាក់ច្បាស់ថា គ្មានអ្វីក្នុងអនុសញ្ញានេះដែលត្រូវយកទៅបកស្រាយថាត្រូវតែប្រែសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋភាគី ក្នុងនាមនៃកតិកាសញ្ញាដទៃទៀតដែលរដ្ឋនោះជាសមាជិកឡើយ។

# ៦ តើអនុសញ្ញាចូលជាធរមាននៅពេលណា ?

## ការផ្តល់សច្ចាប័ន

ដើម្បីក្លាយទៅជាភាគីនៃអនុសញ្ញានេះ រដ្ឋដែលជាសមាជិកនៃអង្គការយូណេស្កូ ត្រូវតម្កល់លិខិតុបករណ៍សម្រាប់ផ្តល់សច្ចាប័ន លិខិតុបករណ៍ព្រមព្រៀង លិខិតុបករណ៍ឯកភាព ឬចូលសមាជិក ផ្ញើជូនទៅអគ្គលេខានៃអង្គការយូណេស្កូ។ រដ្ឋដែលមិនមែនជាសមាជិកនៃអង្គការយូណេស្កូ ប៉ុន្តែជាសមាជិកនៃអង្គការសហប្រជាជាតិ ឬសមាជិកនៃស្ថាប័នឯកទេសណាមួយនៃអង្គការសហប្រជាជាតិ អាចចូលជាសមាជិកនៃអនុសញ្ញានេះបាន លុះត្រាតែរដ្ឋទាំងនោះត្រូវបានអញ្ជើញដោយមហាសន្និបាតនៃអង្គការយូណេស្កូ ។ អង្គការសេដ្ឋកិច្ចតំបន់ដែលកំណត់ដោយអនុសញ្ញានេះ ក៏អាចចូលជាសមាជិកនៃអនុសញ្ញានេះដែរ។

## ការចូលជាធរមាន

អនុសញ្ញានេះនឹងចូលជាធរមាន បីខែបន្ទាប់ពីលិខិតុបករណ៍ទី៣០នៃសច្ចាប័ន លិខិតុបករណ៍ព្រមព្រៀង លិខិតុបករណ៍ឯកភាព ឬចូលសមាជិកត្រូវបានតម្កល់ជូនអគ្គលេខានៃអង្គការយូណេស្កូ។

# ៧ តើអនុសញ្ញាដំណើរការរបៀបដូចម្តេច ?

## យន្តការតាមដាន

នៅពេលដែលអនុសញ្ញាចូលជាធរមានហើយ ស្ថាប័នពីរនឹងត្រូវបង្កើតឡើង:

- សន្និសីទនៃរដ្ឋភាគី ដែលជាអង្គការអធិបតេយ្យ និងពេញអង្គនៃអនុសញ្ញា។
- គណៈកម្មាធិការអន្តររដ្ឋាភិបាល ដែលទទួលបន្ទុកសម្រេចគោលដៅនៃអនុសញ្ញា ព្រមទាំងជួយលើកទឹកចិត្ត និងរ៉ាប់រងនូវការតាមដានការដាក់ឲ្យដំណើរការ ក្នុងស្មារតីនៃតម្លាភាព និងការប្រុងប្រយ័ត្ន។

កិច្ចប្រជុំលើកទី១នៃសន្និសីទនៃរដ្ឋភាគី និងគណៈកម្មាធិការអន្តររដ្ឋាភិបាល ដើរតួនាទីយ៉ាងសំខាន់ មិនត្រឹមតែដើម្បីរៀបចំតាក់តែងបទបញ្ជាផ្ទៃក្នុងនៃអង្គការទាំងពីរនេះប៉ុណ្ណោះទេ តែថែមទាំងត្រូវកំណត់បន្ទាត់ទិសដៅ ដើម្បីដាក់អនុសញ្ញាឲ្យដំណើរការ។ លេខាធិការដ្ឋាននៃអង្គការយូណេស្កូ នឹងចូលរួមក្នុងសន្និសីទនៃរដ្ឋភាគី និងគណៈកម្មាធិការអន្តររដ្ឋាភិបាល។ លេខាធិការដ្ឋាននេះនឹងរៀបចំសំណុំឯកសារ ជួយដល់ការអនុវត្តសេចក្តីសម្រេចចិត្ត និងធ្វើរបាយការណ៍ទៅលើកិច្ចប្រជុំទាំងពីរនោះ។

## មធ្យោបាយ

ក្រៅពីមធ្យោបាយសិទ្ធិនិងកាតព្វកិច្ច មធ្យោបាយជាក់ស្តែងដែលរដ្ឋភាគីត្រូវយកទៅប្រើប្រាស់ គឺមូលនិធិអន្តរជាតិសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ ដែលប្រភពចំណូលបានមកពីវិភាគទានដោយស្ម័គ្រចិត្តនៃរដ្ឋភាគី មូលនិធិដែលបង្កើតឡើងក្នុងគោលដៅនេះដោយមហាសន្និបាតនៃអង្គការយូណេស្កូ និងការផ្ទេរប្រាក់ផ្សេងៗ អំណោយ ឬមត៌ក។

ម្យ៉ាងវិញទៀត ក្នុងក្របខណ្ឌនៃការអនុវត្តន៍អនុសញ្ញា អង្គការយូណេស្កូទទួលបន្ទុកសម្រួលដល់ការប្រមូល វិភាគ និងផ្សព្វផ្សាយរាល់ព័ត៌មាន ស្ថិតិ និងការអនុវត្តដ៏ប្រសើរទាក់ទងទៅនឹងភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។ លើសពីនោះ អង្គការក៏បង្កើត និងធ្វើ

បច្ចុប្បន្នភាពបណ្តាទិន្នន័យស្តីពីផ្នែក និងអង្គការ រដ្ឋាភិបាលផ្សេងៗ ទោះជាឯកជនក្តី មិនគិតចំណេញក្តី ឲ្យតែបំពេញការងារក្នុងវិស័យនេះ។

## ការដោះស្រាយទំនាស់

យន្តការដោះស្រាយទំនាស់ត្រូវបានគ្រោងធ្វើឡើង ក្នុងទស្សនវិស័យវប្បធម៌សុទ្ធសាធ ដើម្បីលាតត្រដាងពីទស្សនៈខុសៗគ្នា ទៅលើការបកស្រាយ និងការអនុវត្តបទបញ្ញា ឬគោលការណ៍មួយចំនួនទាក់ទងទៅនឹងអនុសញ្ញា។

យន្តការនេះតម្រូវឲ្យរដ្ឋភាគីធ្វើការចរចាជាដំបូង មុននឹងអនុញ្ញាតឲ្យប្រើប្រាស់ការផ្សះផ្សារការវិវាទ ឬការផ្សះផ្សាររវាងរដ្ឋ។ ប្រសិនបើមិនអាចដោះស្រាយវិវាទបានតាមរយៈមធ្យោបាយមួយឬច្រើនខាងលើនេះ គេអាចចាប់ផ្តើមនីតិវិធីចរចា។ រដ្ឋភាគីអាចជ្រើសរើសមិនយកនីតិវិធីខាងលើនេះ តាមរយៈសេចក្តីប្រកាសមួយ នៅក្នុងខណៈធ្វើសច្ចាប័ន ព្រមព្រៀង ឯកភាព ឬចូលជាសមាជិក។

# ៨ តើនរណាខ្លះជាអ្នកផានាសំខាន់ៗនៃអនុសញ្ញា?

អនុសញ្ញាអាចប្រព្រឹត្តទៅបានល្អប្រសើរ អាស្រ័យដោយមានការចូលរួមពីអ្នកបំពេញសកម្មភាពវប្បធម៌គ្រប់ៗគ្នា:

- អ្នកបំពេញសកម្មភាពជាបុគ្គលិករដ្ឋ (រដ្ឋ និងស្ថាប័នរដ្ឋ) ដោយមានអនុសញ្ញាជាអ្នកទទួលស្គាល់អធិបតេយ្យភាព។
- អ្នកបំពេញសកម្មភាពនៃសង្គមស៊ីវិល។ អនុសញ្ញាបានអំពាវនាវឲ្យរដ្ឋភាគីទទួលស្គាល់តួនាទីមូលដ្ឋានក្នុងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ទន្ទឹមនឹងនោះ អនុសញ្ញាក៏លើកទឹកចិត្តឲ្យចូលរួមយ៉ាងសកម្មពីសំណាក់សង្គមស៊ីវិល ដើម្បីសម្រេចគោលដៅនៃអនុសញ្ញា។
- អ្នកបំពេញសកម្មភាពជាឯកជន គឺក្រុមហ៊ុន និងឧស្សាហកម្មវប្បធម៌ ជាពិសេសគឺឧស្សាហកម្មនៃប្រទេសកំពុងអភិវឌ្ឍ ដែលអនុសញ្ញាបានអំពាវនាវឲ្យជួយលើកស្ទួយបទបញ្ញត្តិរបស់ខ្លួន ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍។
- ទីបញ្ចប់ គឺជនដែលស្ថិតនៅក្នុងចំណោមជនជាតិភាគតិច និងជនជាតិដើម ត្រូវបាទទួលស្គាល់ថាជាអ្នកបំពេញសកម្មភាពគន្លឹះ ហើយក្នុងន័យនេះ គេបានអំពាវនាវដល់រដ្ឋភាគីឲ្យគិតទៅដល់លក្ខខណ្ឌ និងតម្រូវការពិសេសរបស់ពួកគេ ឲ្យបានត្រឹមត្រូវ ក្នុងវិស័យនៃការបង្កើតថ្មី។

# ៩ តើនរណាខ្លះជាអ្នកទទួលអត្ថប្រយោជន៍ពីអនុសញ្ញា?

អ្នកដែលទទួលអត្ថប្រយោជន៍ពីអនុសញ្ញាមិនត្រូវមានចំនួនកម្រិតឡើយ:

- នៅក្នុងស្មារតីរបស់ខ្លួន អនុសញ្ញាផ្តល់នូវអត្ថប្រយោជន៍ដល់បុគ្គល និងសង្គម ព្រោះវាមានបំណងធានាដល់អ្នកទាំងអស់នូវសេចក្តីរីករាយដោយសារ ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដោយធ្វើយ៉ាងណាឲ្យមានការបើកទូលាយ លំនឹង និងសេរីភាព។
- ដោយទទួលស្គាល់ពីការចូលរួមយ៉ាងសំខាន់ពីសំណាក់សិល្បករ និងរាល់អ្នកទាំងឡាយណាដែលចូលរួមក្នុងដំណើរការបង្កើតថ្មី ពីសំណាក់សហគមន៍វប្បធម៌ និង

អង្គការដែលគាំទ្រការងារអ្នកទាំងនោះ អនុសញ្ញាផ្តល់អត្ថប្រយោជន៍ខ្លាំងជាងគេ ដល់អ្នកមានវិជ្ជាជីវៈ និងអ្នកបំពេញការងារផ្នែកវប្បធម៌។

ម្យ៉ាងវិញទៀត បទបញ្ញត្តិខ្លះៗនៃអនុសញ្ញា កំណត់អត្ថន័យអ្នកទទួលបានអត្ថប្រយោជន៍ ជាពិសេសថាជាៈ

- ប្រទេសដែលខ្វះសមត្ថភាពផលិតកម្ម និងផ្សព្វផ្សាយវិញ្ញត្តិវប្បធម៌របស់ខ្លួន និង ជាពិសេសប្រទេសកំពុងអភិវឌ្ឍ។ អនុសញ្ញាគ្រោងទុកនូវជំនួយជាច្រើនបែបផ្សេង គ្នាចំពោះវិធានការទាំងនោះ (ជំនួយសាធារណៈដល់ការអភិវឌ្ឍ កម្ចីការប្រាក់ ទាប ការឧបត្ថម្ភជាទឹកប្រាក់ ។ល។) ព្រមទាំងការយកចិត្តទុកដាក់ជាងគេចំពោះ សិល្បករ និងអ្នកមានអាជីព និងអ្នកបំពេញការងារផ្នែកវប្បធម៌ ដែលមកពីប្រទេស ទាំងនោះ។

- ក្រុមមនុស្សក្នុងសង្គម រួមទាំងស្ត្រី ជនជាតិភាគតិច និងជនជាតិដើម ដោយមាន ចែងពីកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចរបស់រដ្ឋភាគី ក្នុងការបង្កើតបរិស្ថាន សមស្របសម្រាប់ការបង្កើតថ្មី ផលិតកម្ម ការផ្សព្វផ្សាយ និងការទទួលបានអត្ថ ប្រយោជន៍ពីវិញ្ញត្តិវប្បធម៌នៃក្រុមមនុស្សនោះ។

## ១០ តើគោលគំនិតសំខាន់ៗនៃអនុសញ្ញាមានអ្វីខ្លះ?

អនុសញ្ញាកំណត់ថាគំនិតបង្កើតថ្មីនៃវប្បធម៌ ដែលជាផ្នែកមួយនៃភាពផ្សេងគ្នានៃវប្បធម៌ ត្រូវចែករំលែកទៅមនុស្សជាតិ។ អនុសញ្ញានេះបើកផ្លូវឆ្ពោះទៅរកការរឹតចំណងទាក់ ទងរវាងមនុស្សនៅលើពិភពលោក ដែលទទួលរងនូវសាកលភាវូបនីយកម្ម តែមិនទាន់ មានសាមគ្គីភាពគ្រប់គ្រាន់នៅឡើយ។ ក្នុងខណៈដែលការផ្គត់ផ្គង់វប្បធម៌មិនដែលធ្លាប់ ពង្រីកឲ្យមានចំនួនច្រើនបែបនេះ អនុសញ្ញានឹងធ្វើអន្តរាគមន៍ដើម្បីឲ្យមនុស្សមួយចំនួន ធំទទួលបានអត្ថប្រយោជន៍ ធ្វើយ៉ាងណាមិនឲ្យជម្រើសស្នាដៃរបស់ពួកគេស្ថិតនៅតែ ក្នុងចំណោមមនុស្សភាគតិច ទោះជាពួកគេនៅក្នុង ឬក្រៅប្រទេសក៏ដោយ។

អនុសញ្ញាមានគោលដៅការពារភាពសម្បូរបែបផ្នែកវប្បធម៌ ដែលទាញយកសមត្ថភាព ធ្វើសកម្មភាពទាក់ទងគ្នាទៅវិញទៅមក ធ្វើសកម្មភាពសាជាថ្មី និងផ្ទេរចំណេះដឹង ចេញ ពីប្រភពផ្ទៃក្នុង និងពីពិភពលោកទាំងមូល។ ការដាក់ឲ្យដំណើរការដ៏ធំទូលាយនៃភាព ផ្សេងគ្នាបង្កើតថ្មីនេះ ទោះជាមកពីប្រភពខាងក្នុង ឬខាងក្រៅក៏ដោយ សុទ្ធតែមានអត្ថ ប្រយោជន៍វប្បធម៌ និងសង្គម ដែលរំលងហួសពីលក្ខណៈពាណិជ្ជកម្មរបស់វា។

អនុសញ្ញាមិនមានបំណងត្រួតពិនិត្យ ឬបង្ខំឡើយ តែប្រាថ្នាចង់លើកស្ទួយនិងការ ពារភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌។ អត្ថន័យនៃការការពារគឺជានាវាល់សកម្មភាព និង មធ្យោបាយដែលប្រើប្រាស់ដោយរដ្ឋភាគីនីមួយៗដែលសិទ្ធិអធិបតេយ្យត្រូវបានទទួល ស្គាល់ សំដៅអភិរក្ស រក្សា និងលើកតម្កើងភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ គឺមិនកម្រិត ត្រឹមលំហូរ នៃការទទួលកិច្ចការពារពីរដ្ឋ និងការគិតទៅលើអត្តសញ្ញាណនៃប្រទេស នីមួយៗនោះឡើយ។ កិច្ចធានាផ្សេងៗត្រូវបានតាក់តែងឡើងដោយអនុសញ្ញា ដែលនៅ ក្នុងនោះ "គោលការណ៍បើកទូលាយ និងលំនឹង" ធានាថាវិធានការដែលអនុម័តដោយ រដ្ឋនានាក៏ត្រូវលើកស្ទួយនូវ "ការបើកទ្វារទៅរកវប្បធម៌ផ្សេងទៀតក្នុងពិភពលោក" ផង ដែរ។

អនុសញ្ញាអាចឲ្យរដ្ឋភាគីចាត់វិធានការការពារ ក្នុងករណីដែលវិញ្ញត្តិវប្បធម៌ទទួលរងនូវ ហានិភ័យនៃការបាត់បង់ ឬការគំរាមធ្ងន់ធ្ងរ ហើយសហប្រតិបត្តិការអន្តរជាតិក៏ត្រូវបាន ជំរុញឲ្យជួយប្រទេសកំពុងអភិវឌ្ឍដើម្បីប្រឈមមុខទៅនឹងស្ថានភាពបែបនោះ។ ទោះ ជាក្នុងករណីណាក៏ដោយ គេត្រូវគោរពតាមគោលដៅ និងគោលការណ៍នៃអនុសញ្ញា ពីព្រោះវាសំដៅសម្រួលដល់ការផ្លាស់ប្តូរគំនិតគ្នាដ៏ពិតប្រាកដ រវាងវិញ្ញត្តិវប្បធម៌នៃ ប្រជាជនគ្រប់ប្រទេស និងលើកតម្កើងភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ទាំងនៅក្នុង ប្រទេស និងនៅលើឆាកអន្តរជាតិ។

ក្នុងសកម្មភាពនោះ អនុសញ្ញាចូលរួមរឹតចំណងទាក់ទងរវាង់ វប្បធម៌ និងការអភិវឌ្ឍន៏។ ពាក្យថាការអភិវឌ្ឍន៍នេះ ត្រូវបានប្រើប្រាស់ក្នុងន័យទ្វេ គឺទាំងក្នុងផ្នែកសម្ភារៈផង និងនិមិត្តរូបផងៈ ទី១ ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច និងទី២ សេចក្តីរីករាយរបស់មនុស្សដែលទទួលបានអត្ថប្រយោជន៍ពីសិទ្ធិមូលដ្ឋាន បើកទូលាយទៅពិភពលោក ដោយឥតបាត់បង់អត្តសញ្ញាណរបស់ខ្លួន។ អនុសញ្ញាបង្កើតជាមូលដ្ឋានសហប្រតិបត្តិការដែលតែងតែធ្វើសាជាថ្មី និងសាមគ្គីភាពក្នុងប្រទេស ក្នុងតំបន់ និងលើឆាកអន្តរជាតិ ដោយសម្រួលឲ្យមានការផ្លាស់ប្តូរគំនិតគ្នា និងកិច្ចសហការជាដៃគូ ដែលផ្តល់ប្រយោជន៍ដល់ប្រទេសដែលវិញ្ញត្តិវប្បធម៌មានបញ្ហា។

ទីបញ្ចប់ អនុសញ្ញាទទួលស្គាល់ និងបង្កើតនូវទម្រង់នៃការពិភាក្សាថ្មី ចេញពីទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ដែលផ្សព្វផ្សាយ និងធ្វើយ៉ាងណាឲ្យវិញ្ញត្តិវប្បធម៌ទៅដល់ដៃមនុស្សគ្រប់គ្នា ៖ ទម្រង់បង្កើតថ្មីនីមួយៗបង្កើតបានជាទីជំនួបមួយ បើកជើងមេឃថ្មី ធ្វើឲ្យទស្សនវិស័យមានការផ្លាស់ប្តូរ ពង្រីកលំហនៃសេរីភាព និងជម្រើសដែលជួយចូលរួមឆ្នៃបង្កើតពិភពលោកឲ្យមានលក្ខណៈមនុស្សជាតិជាងពេលមុន។ ទម្រង់បង្កើតថ្មីនីមួយៗបង្កើតបានជាទំនាក់ទំនងរវាងតំបន់ កសាងនូវប្រភពនៃបេតិកភណ្ឌមួយនៅថ្ងៃអនាគត។

ដោយគិតទៅដល់ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ អនុសញ្ញាចូលរួមធ្វើឲ្យ "ការការពារភាពផ្សេងៗគ្នានៃវប្បធម៌ក្លាយទៅជាកំហិតក្រមសីលធម៌ ដែលនៅមិនដាច់ពីគ្នាពីការការគោរពភាពថ្លៃថ្នូរនៃបុគ្គលជាមនុស្ស "។ ដោយយកចិត្តទុកដាក់ទៅលើថ្មីទៅលើវិញ្ញត្តិវប្បធម៌ និងក្នុងការគោរពពេញលេញទៅលើការផ្សព្វផ្សាយជាសេរី រដ្ឋសមាជិកនៃអង្គការយូណេស្កូសំដែងចេញនូវការទទួលខុសត្រូវចំពោះមុខប្រភពមិនចេះរីងស្ងួតនៃការបង្កើតថ្មី ការច្នៃប្រឌិតថ្មី ការស្រមៃ ដើម្បីការយោគយល់គ្នាទៅវិញទៅមក និងការពិភាក្សាគ្នារវាងវប្បធម៌ផ្សេងៗ។

- អនុសញ្ញាសាកលស្តីពីសិទ្ធិអ្នកនិពន្ធ (ឆ្នាំ១៩៥២ ប្រែសម្រួលឡើងវិញនៅឆ្នាំ ១៩៧១)
- អនុសញ្ញាស្តីពីការការពារសម្បត្តិវប្បធម៌ ក្នុងករណីមានជម្លោះប្រដាប់អាវុធ (ឆ្នាំ ១៩៥៤) (ពិធីសារទី១ ឆ្នាំ១៩៥៤, ពិធីសារទី២ ឆ្នាំ១៩៩៩ )
- អនុសញ្ញាទាក់ទងនឹងវិធានការដែលត្រូវចាត់ឡើងដើម្បីហាមឃាត់ និងទប់ស្កាត់កុំឲ្យមានការនាំចូល នាំចេញ និងផ្ទេរកម្មសិទ្ធិមិនស្របច្បាប់នៃសម្បត្តិវប្បធម៌ (ឆ្នាំ ១៩៧០)
- អនុសញ្ញាទាក់ទងនឹងការការពារបេតិកភណ្ឌពិភពលោក វប្បធម៌ និងធម្មជាតិ (ឆ្នាំ ១៩៧២)
- អនុសញ្ញាស្តីពីការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក (ឆ្នាំ២០០១)
- អនុសញ្ញាស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី (ឆ្នាំ២០០៣)
- អនុសញ្ញាស្តីពីការការពារ និងលើកស្ទួយភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ (ឆ្នាំ ២០០៥)

អនុសញ្ញាស្តីពីការការពារ និងលើកស្ទួយភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ ខុសប្លែកពីអនុសញ្ញានានាទាក់ទងនឹងបេតិកភណ្ឌ ពីព្រោះ ដំបូងបង្អស់ អនុសញ្ញានេះគិតទៅដល់ភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ ដូចដែលគេមានដាក់ឲ្យចរាចរណ៍ និងចែករំលែកដោយសកម្មភាពនានា គឺសម្បត្តិនិងសេវាកម្មវប្បធម៌ ដែលជាកត្តាសម័យទំនើបដ៏សំខាន់ ដ៏ប្រសើរនៃវប្បធម៌។

អនុសញ្ញានេះបំពេញបន្ថែមប្រកបដោយអត្ថប្រយោជន៍ ទៅលើវិធានគតិយុត្តិដែលអង្គការយូណេស្កូអនុវត្ត ដើម្បីជាប្រយោជន៍ដល់ភាពផ្សេងគ្នាបែបច្នៃប្រឌិត និងដើម្បីសម្រួលដល់បរិស្ថានពិភពលោក ដែលការប្រឌិតនៃបុគ្គលម្នាក់ៗ និងប្រជាជននានាត្រូវបានការពារទៅតាមភាពខុសគ្នាប្រកបដោយភាពសម្បូរបែបរបស់វា។

## ២ តើកម្មវត្ថុនៃអនុសញ្ញាមានអ្វីខ្លះ?

អនុសញ្ញាស្តីពីការការពារ និងលើកស្ទួយភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌មិនទាក់ទងទៅនឹងរាល់ទិដ្ឋភាពនៃភាពផ្សេងគ្នានៃវប្បធម៌ឡើយ គឺដូចមានចែងនៅក្នុងសេចក្តីប្រកាសជាសាកលរបស់អង្គការយូណេស្កូ ស្តីពីវិញ្ញត្តិវប្បធម៌។ អនុសញ្ញានេះសំដៅ ទៅលើដែនប្រធានបទច្បាស់លាស់មួយចំនួន ដូចមានចែងពីមាត្រាទី៨ ដល់ទី១១ រួមមាន ខ១ ភាពចាំបាច់ក្នុងការទទួលស្គាល់ថាសម្បត្តិ និងសេវាកម្មវប្បធម៌សុទ្ធតែជាសារធាតុទ្រទ្រង់អត្តសញ្ញាណ គុណធម៌ និងអត្ថន័យ ហើយមិនអាចចាត់ទុកជាទំនិញ ឬជាសម្បត្តិដែលត្រូវយកទៅប្រើប្រាស់ឲ្យដូចជាអ្វី ផ្សេងទៀតឡើយ។ ខ២ ភាពចាំបាច់សម្រាប់រដ្ឋនានាក្នុងការចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ហើយក្នុងពេលជាមួយគ្នានោះត្រូវធានាឲ្យបាននូវការផ្សព្វផ្សាយគំនិត និងស្នាដៃ។ ខ៣ ភាពចាំបាច់ក្នុងការកំណត់ឡើងវិញនូវកិច្ចសហប្រតិបត្តិការអន្តរជាតិដែលជាចំណុចសំខាន់នៃអនុសញ្ញា ពីព្រោះទម្រង់ច្នៃប្រឌិតនីមួយៗសុទ្ធតែជាពន្លកនៃការសន្ទនាគ្នាជាអចិន្ត្រៃយ៍។

វត្ថុបំណងនៃអនុសញ្ញាគឺធ្វើឲ្យវិញ្ញត្តិវប្បធម៌មានទម្រង់ច្រើនខុសៗគ្នា។ វិញ្ញត្តិវប្បធម៌ទាំងនោះកើតចេញពីគំនិតច្នៃប្រឌិតរបស់បុគ្គល ក្រុម និងសង្គម ជាមួយនឹងខ្លឹមសារវប្បធម៌ដែលផ្សារភ្ជាប់ទៅនឹងអត្ថន័យជានិមិត្តរូប លក្ខណៈសម្បត្តិសិល្បៈ និងទៅលើតម្លៃវប្បធម៌ ដោយមានអត្តសញ្ញាណវប្បធម៌ជាប្រភពដើម ហើយសម្តែងចេញនូវអត្តសញ្ញាណវប្បធម៌នោះឡើង។ ទោះបីជាឧបករណ៍ និងបច្ចេកវិទ្យាដែលយកមកប្រើប្រាស់មានលក្ខណៈបែបណាក៏ដោយ ក៏គេត្រូវផ្ទេរចំណេះដឹងនៃវិញ្ញត្តិវប្បធម៌ទាំងនេះ

# ឯកសារទាក់ទងនឹងអនុសញ្ញា

Preliminary draft convention on the protection of the diversity of cultural contents and artistic expressions, Preliminary report of the Director-General, CLT/CPD/2004/CONF.201/1, Paris, July 2004.

Preliminary draft of a convention on the protection of the diversity of cultural contents and artistic expressions, CLT/CPD/2004/CONF.201/2, Paris, July 2004.

First session of the intergovernmental meeting of experts on the Preliminary draft convention on the protection of the diversity of cultural contents and artistic expressions, Report by the Secretariat, CLT-2004/CONF.201/9, Paris, November 2004.

Preliminary draft convention on the protection of the diversity of cultural contents and artistic expressions, Drafting Committee, Part I to V, Paris, December 2004, CLT/CPD/2004/CONF.607/1 to CLT/CPD/2004 CONF.607/5.

Preliminary draft convention on the protection of the diversity of cultural contents and artistic expressions, Text revised by the Drafting Committee,

CLT/CPD/2004/CONF.607/6, Paris, December 2004.

Preliminary report of the Director-General containing two preliminary drafts of a Convention on the protection of the diversity of cultural contents and artistic expressions, CLT/CPD/2005/CONF.203/6, Paris, 3 March 2005.

Report by the Director-General on the progress towards the draft convention on the protection of the diversity of cultural contents and artistic expressions, 171 EX/Decision 19, April 2005.

Appendix 2 to the Preliminary report of the Director-General containing two preliminary drafts of a Convention on the protection of the diversity of cultural contents and artistic expressions, Consolidated text prepared by the Chairperson of the intergovernmental meeting, CLT/CPD/2005/CONF.203/6 - Add, Paris, 29 April 2005.

Preliminary report by the Director-General setting out the situation to be regulated and the possible scope of the regulating action proposed, accompanied by the Preliminary draft of a convention on the protection of the diversity of cultural contents and artistic expressions, 33 C/23, Paris, 4 August 2005.

Report by the Director-General on the progress achieved during the third session of the intergovernmental meeting of experts on the preliminary draft convention on the protection of the diversity of cultural contents and artistic expressions, 172 EX/Decision 19, September 2005.

Convention on the Protection and Promotion of the Diversity of Cultural Expressions, 20 October 2005, 33rd session of the General Conference.



KH/2010/CL/CON2/31
Phnom Penh, October 2010
Original: English

៣០សំណួរ

# ៣០សំណួរ ដែលគេតែងតែ ចោទសួរ ទាក់ទងនឹង

## អនុសញ្ញាស្តីពី ការការពារ និងការលើកស្ទួយ

## ភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌

UNESCO
United Nations
Educational, Scientific and
Cultural Organization

# ៣០សំណួរ ដែលគេតែងតែ ចោទសួរ ទាក់ទងនឹង

## អនុសញ្ញាស្តីពី ការការពារ និងការលើកស្ទួយ

# ភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌


បរិបទ ........................................ 2
១- តើអ្វីទៅជាអនុសញ្ញាស្តីពីការការពារ និងលើកស្ទួយភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ ? ........ 2
២- តើអ្វីទៅជា ភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ ? ........ 2
៣- តើបញ្ហាប្រឈមនៃអនុសញ្ញាមានអ្វីខ្លះ ? ........ 3
៤- តើមូលដ្ឋានទ្រឹស្តីនៃអនុសញ្ញាមានអ្វីខ្លះ ? ........ 3
៥- ហេតុអ្វីក៏អនុសញ្ញាមិនចាត់ចែងភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ជាលក្ខណៈរួម ? ........ 4
៦- តើដំណាក់កាលអ្វីខ្លះដែលនាំឲ្យកើតមានការអនុម័តអនុសញ្ញា ? ........ 4

អត្ថបទ ........................................ 6
៧- តើគោលដៅនៃអនុសញ្ញាមានអ្វីខ្លះ ? ........ 6
៨- តើដែនអនុវត្តនៃអនុសញ្ញាមានត្រឹមណា ? ........ 6
៩- តើសិទ្ធិអ្វីខ្លះដែលអនុសញ្ញាទទួលស្គាល់សម្រាប់រដ្ឋភាគី ? ........ 7
១០- តើកាតព្វកិច្ចអ្វីខ្លះដែលអនុសញ្ញាដាក់ជូនរដ្ឋភាគី ? ........ 8
១១- តើតួនាទីនៃសហប្រតិបត្តិការអន្តរជាតិនៅក្នុងអនុសញ្ញាមានដូចម្តេចខ្លះ ? ........ 8
១២- តើគោលការណ៍ចង្អុលទិសសកម្មភាពនៃរដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញាមានដូចម្តេចខ្លះ ? ........ 9

ការអនុវត្តនៃអនុសញ្ញា ........................................ 10
១៣- តើអនុសញ្ញានឹងចូលជាធរមាននៅពេលណា ? ........ 10
១៤- តើត្រូវប្រើនីតិវិធីបែបណាដើម្បីផ្តល់សច្ចាប័នដល់អនុសញ្ញា ? ........ 10
១៥- តើយន្តការនៃការតាមដានមានដូចម្តេចខ្លះ ? ........ 11
១៦- តើអ្វីទៅជាសន្និសីទនៃរដ្ឋភាគី ? តើមុខងារនៃសន្និសីទនោះមានអ្វីខ្លះ ? ........ 11
១៧- តើអ្វីទៅជាគណៈកម្មាធិការអន្តររដ្ឋាភិបាល ? តើមុខងារនៃគណៈកម្មាធិការនោះមានអ្វីខ្លះ ? ........ 11
១៨- តើមុខងារនៃលេខាធិការដ្ឋាននៃអង្គការយូណេស្កូមានអ្វីខ្លះ ........ 12
១៩- តើតួនាទីនៃសង្គមស៊ីវិលក្នុងការអនុវត្តន៍អនុសញ្ញាមានដូចម្តេចខ្លះ ? ........ 12
២០- តើអ្វីទៅជាមូលនិធិអន្តរជាតិដើម្បីភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ? ........ 12
២១- តើយន្តការនៃការដោះស្រាយជម្លោះដំណើរការយ៉ាងដូចម្តេច ? ........ 13
២២- តើអនុសញ្ញានេះមានកំណត់ទំនាក់ទំនងជាមួយនឹងលិខិតុបករណ៍គតិយុត្តិអន្តរជាតិផ្សេងៗទៀតដែរឬទេ ? ........ 13
២៣- តើអនុសញ្ញាមានទំនាក់ទំនងជាមួយលិខិតុបករណ៍អន្តរជាតិតាមរបៀបដូចម្តេចខ្លះ ? ........ 14

សេចក្តីបញ្ចប់ ........................................ 15
២៤- តើសារប្រយោជន៍ក្នុងការធ្វើសច្ចាប័នទៅលើអនុសញ្ញាមានដូចម្តេចខ្លះ ? ........ 15
២៥- តើប្រទេសកំពុងអភិវឌ្ឍទទួលបានអត្ថប្រយោជន៍អ្វីខ្លះ ? ........ 15
២៦- តើអនុសញ្ញាគិតគូរដល់មនុស្សដែលស្ថិតនៅក្នុងចំណោមជនជាតិភាគតិច និងជនជាតិដើមឬទេ ? ........ 16
២៧- តើអនុសញ្ញាមានគិតដល់កម្មសិទ្ធិបញ្ញាដែរឬទេ ? ........ 16
២៨- តើអនុសញ្ញាគិតគូរដល់ភាពផ្សេងៗគ្នានៃភាសាដែរឬទេ ? ........ 16
២៩- តើអនុសញ្ញាកំហិតការផ្សព្វផ្សាយដោយសេរីនូវគំនិត និងព័ត៌មានដែរឬទេ ? តើអនុសញ្ញាបញ្ជាក់ប្រាប់ពីមូលហេតុនៃការត្រួតពិនិត្យព័ត៌មានដែរឬទេ ? ........ 17
៣០- តើអនុសញ្ញាអាចជះឥទ្ធិពលដល់របបពាណិជ្ជកម្មនៃរដ្ឋភាគីដែរឬទេ ? ........ 18

## បរិបទ

### ១ តើអ្វីទៅជាអនុសញ្ញាស្តីពីការការពារ និងលើក ស្ទួយភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ ?

សៀវភៅ ស៊ីឌី ទស្សនីយភាព កម្មវិធីវិទ្យុ ឬទូរទស្សន៍ ខ្សែភាពយន្ត វីដេអូ ឌីវីឌី ឬអ៊ីនធឺណិត ៖ បច្ចុប្បន្ននេះ គំនិត និងវិញ្ញត្តិវប្បធម៌មួយផ្នែកធំសុទ្ធតែឆ្លងតាមរយៈច្រវាក់ផលិតកម្ម និងការផ្សព្វផ្សាយដែលកាន់តែមានលក្ខណៈបច្ចេកទេសនិងឧស្សាហកម្មខ្លាំងឡើងៗ ។ ចំពោះមុខការផ្លាស់ប្តូរដ៏ខ្លាំងក្លានៃបែបបទបង្កើតថ្មី និងការទទួលបាននូវវប្បធម៌នេះ គប្បីចោទសួរខ្លួនឯងថា តើអ្នកទាំងអស់គ្នាទទួលបានអត្ថប្រយោជន៍ដូចៗគ្នាដែរឬទេ?

អនុសញ្ញាស្តីពីការការពារនិងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដែលអនុម័តឡើងនៅឆ្នាំ២០០៥ ដោយមហាសន្និបាតនៃអង្គការយូណេស្កូ គឺជាលិខិតុបករណ៍គតិយុត្តិអន្តរជាតិដែលមានលក្ខណៈតឹងតែង។ អនុសញ្ញានេះមានគោលបំណងការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដែលសម្រេចឡើង និងផ្ទេរដោយសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ដែលជាកត្តាសម័យថ្មីនៃវប្បធម៌។ អនុសញ្ញាមានបំណងបង្កើតជាក្របខណ្ឌគតិយុត្តិដ៏សមស្របមួយសម្រាប់ជនគ្រប់រូប សម្រាប់ការបង្កើត ផលិតកម្ម ការបែងចែក/ផ្សព្វផ្សាយ ព្រមទាំងការទទួលបាន និងសេចក្តីរីករាយចំពោះវិញ្ញត្តិវប្បធម៌ដ៏ប្លែកៗគ្នាយ៉ាងខ្លាំង ដែលមកពីប្រភពផ្សេងៗគ្នា។

អនុសញ្ញាគូសបញ្ជាក់យ៉ាងច្បាស់ពីតួនាទីដ៏សំខាន់នៃនយោបាយវប្បធម៌ និងកំណត់សិទ្ធិនិងកាតព្វកិច្ចនៃរដ្ឋភាគី ក្នុងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិ។ រដ្ឋភាគីត្រូវយល់ស្របចំពោះលក្ខណៈបន្ទាន់នៃលិខិតុបករណ៍នេះ ក្នុងខណៈដែលសន្ទុះនៃសាកលភាវូបនីយកម្មកំពុងតែបង្កើននូវគម្លាតរវាងប្រទេសដែលខ្វះសមត្ថភាពក្នុងការបង្កើតផលិត និងផ្សព្វផ្សាយវិញ្ញត្តិវប្បធម៌ និងប្រទេសដែលមានសមត្ថភាពនោះ។

### ២ តើអ្វីទៅជា "ភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌" ?

ដែលហៅថាវិញ្ញត្តិវប្បធម៌ គឺជាការសំដែងចេញផ្សេងៗនៃការបង្កើតថ្មីរបស់បុគ្គល និងក្រុមមនុស្សក្នុងសង្គម។ ការសំដែងចេញនោះមានដូចជា វិញ្ញត្តិដោយប្រើប្រាស់ពាក្យពេចន៍ (អក្សរសិល្ប៍, រឿងនិទាន...) សំលេង (តន្ត្រី...) រូបភាព (រូបថត ភាពយន្ត...) ទោះជាប្រើឧបករណ៍អ្វីក៏ដោយ (ក្រដាសបោះពុម្ពឯកសារសោតទស្សន៍ កុំព្យូទ័រ។ល។ ) ឬក៏តាមរយៈសកម្មភាព (របាំ ល្ខោន...) ឬវត្ថុផ្សេងៗ (ចម្លាក់ រូបវិចិត្រកម្ម...)។

បច្ចុប្បន្ន វិញ្ញត្តិវប្បធម៌កាន់តែប្រកាន់យកគោលការណ៍ឧស្សាហកម្ម និងសេដ្ឋកិច្ច នៅក្នុងការផលិត និងផ្សព្វផ្សាយវាឡើង។ ដូច្នេះ គេអាចអះអាងបានថា វិញ្ញត្តិវប្បធម៌មួយចំណែកត្រូវបានផ្សព្វផ្សាយតាមរយៈ "សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ " ដែលសព្វថ្ងៃ ជាកត្តាចម្បងនៃវប្បធម៌។ សកម្មភាពទាំងនេះបានបង្កើតឲ្យមាននូវសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ហើយក្លាយទៅជាគោលដៅពាណិជ្ជកម្មអន្តរជាតិ។ ក្នុងន័យនេះ លក្ខណៈទ្វេ គឺលក្ខណៈសេដ្ឋកិច្ចផង និងវប្បធម៌ផងនៃសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ត្រូវបានគេទទួលស្គាល់ជាបណ្តើរៗ ហើយដោយហេតុថាវាផ្ទុកនូវអត្ត

សញ្ញាណ គុណធម៌ និងអត្ថន័យ គេមិនអាចយកវាទៅដោះដូរដូចជាផលិតផលពាណិជ្ជកម្មបានឡើយ។ ដោយគិតទៅដល់ការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ អនុសញ្ញានាឆ្នាំ២០០៥ បានគូសបញ្ជាក់ថា នៅក្នុងពិភពលោកមួយដែលកាន់តែមានទំនាក់ទំនងរវាងគ្នាកាន់តែខ្លាំងឡើង បុគ្គលម្នាក់ៗអាចទទួលបានអត្ថប្រយោជន៍កាន់តែទូលាយឡើងនិងកាន់តែឆាប់រហ័សឡើងនូវភាពផ្សេងៗគ្នាដ៏សម្បូរបែបនៃវិញ្ញត្តិវប្បធម៌ដែលមកពីក្នុង ឬពីក្រៅប្រទេស។ ប៉ុន្តែលទ្ធភាពនេះមិនទាន់មានពេញលេញនៅឡើយ ព្រោះវាធ្វើឡើងក្នុងបរិបទនៃសាកលភាវូបនីយកម្ម ដែលនៅមិនទាន់មានសាមគ្គីភាពគ្រប់គ្រាន់នៅឡើយ។

## ៣ តើបញ្ហាប្រឈមនៃអនុសញ្ញាមានអ្វីខ្លះ?

អនុសញ្ញាសំដៅផ្តល់ដល់វប្បធម៌ នូវតួនាទីមួយត្រឹមត្រូវ ក្នុងទិនានុលេខន៍នយោបាយអន្តរជាតិ ជាពិសេសដោយទទួលស្គាល់នូវតម្លៃនិមិត្តរូប ដែលមិនអាចផ្តាច់ចេញពី សុខុមាលភាពរបស់មនុស្សជាតិ។ បើនិយាយឲ្យច្បាស់ជាងនេះទៅទៀត អនុសញ្ញាលើកឡើងនូវបញ្ហាប្រឈមជាច្រើន ដែលវិញ្ញត្តិវប្បធម៌ត្រូវជួបប្រទះក្នុងសម័យកាលយើងនេះ គឺ:

- ទទួលស្គាល់លក្ខណៈទ្វេ គឺលក្ខណៈសេដ្ឋកិច្ចផង និងវប្បធម៌ផងនៃសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ដែលផ្សព្វផ្សាយ និងផ្ទេរវិញ្ញត្តិវប្បធម៌ ហើយជាមួយនឹងទង្វើបែបនេះ សកម្មភាពទាំងនោះជាអ្នកផ្ទុកនូវអត្តសញ្ញាណ គុណធម៌ និងអត្ថន័យ ដែលដាច់ចេញពីតម្លៃពាណិជ្ជកម្មរបស់វា។

- ចៀសវាងនូវការធ្វើឲ្យប៉ះពាល់ដល់វិញ្ញត្តិវប្បធម៌នៅក្នុងក្រុមមនុស្សផ្សេងៗក្នុងសង្គម រួមទាំងជនជាតិភាគតិចនិងជនជាតិដើម។

- ដោះស្រាយបញ្ហាហានិភ័យដោយសារការបាត់លំនឹងនៃលំហូរនៃវិញ្ញត្តិវប្បធម៌ រវាងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ។

## ៤ តើមូលដ្ឋានទ្រឹស្តីនៃអនុសញ្ញាមានអ្វីខ្លះ?

អនុសញ្ញាស្ថិតនៅក្នុងផ្នត់គំនិត និងសកម្មភាពនៃអង្គការយូណេស្កូ ។ តាមរយៈសារលិខិតជាបតិដ្ឋាប័នរបស់ខ្លួន អង្គការយូណេស្កូមានបេសកកម្មពីរ ម៉្យាង "ធានាដល់រដ្ឋសមាជិក[...]នូវភាពផ្សេងៗគ្នាដ៏សម្បូរបែប" និងម៉្យាងទៀត "សម្រួលដល់ចំណេះដឹង និងការយោគយល់គ្នាទៅវិញទៅមក រវាងប្រជាជាតិ ដោយជួយដល់អង្គការព័ត៌មានសម្រាប់ប្រជាជនទូទៅ [និងដោយ] សំណូមពរឲ្យមានការព្រមព្រៀងដែលគេគិតថាមានប្រយោជន៍ ដើម្បីសម្រួលដល់ការផ្សព្វផ្សាយគំនិតតាមរយៈពាក្យពេចន៍និងរូបភាព" ។ រវាងឆ្នាំ១៩៤៥ និងបច្ចុប្បន្ន បញ្ហានៃភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ត្រូវបានលើកឡើងមកពិភាក្សាដោយផ្ទាល់ ឬមិនផ្ទាល់ ដោយអង្គការយូណេស្កូ ទៅតាមបរិបទប្រវត្តិសាស្ត្រ និងនយោបាយផ្សេងៗគ្នា។ ចាប់តាំងពីឆ្នាំ១៩៩០មក ដើម្បីឆ្លើយតបទៅនឹងសន្ទុះនៃដំណើរការសាកលភាវូបនីយកម្ម ការចោទសួរនោះក៏ក្លាយទៅជារឿងសំខាន់ជាងគេ ជាពិសេសនៅក្នុងសន្និសីទអន្តររដ្ឋាភិបាល ស្តីពីនយោបាយវប្បធម៌ដើម្បីអភិវឌ្ឍ (ទីក្រុងស្តុកខុលម៍ ឆ្នាំ១៩៩៨) ដែលផែនការសកម្មភាពទទួលបានពីការសិក្សាជាច្រើន មានសន្និសីទ និងកិច្ចប្រជុំគុម្មលនៃរដ្ឋមន្ត្រីក្រសួងវប្បធម៌ ព្រមទាំងការបោះពុម្ពផ្សាយនូវរបាយការណ៍ស្តីពីវប្បធម៌នៅក្នុងពិភពលោក។ នៅក្នុងន័យនេះ របាយការណ៍ពិភពលោកចំនួនពីរស្តីពីវប្បធម៌ក៏លេចរូបរាងឡើង: *វប្បធម៌ ការបង្កើតថ្មី និងទីផ្សារ* (ឆ្នាំ១៩៩៨) និង *ភាពផ្សេងៗគ្នា ទំនាស់ និងពហុនិយម* (ឆ្នាំ២០០០) ។ នៅឆ្នាំ២០០១ ដោយទទួលបានដកពិសោធន៍ពីការសិក្សាដែលធ្វើរួចមក មហាសន្និបាត

បានអនុម័តជាឯកច្ឆន្ទនូវសេចក្ដីប្រកាសជាសាកលនៃអង្គការយូណេស្កូ ស្ដីពីភាពផ្សេងៗគ្នានៃវប្បធម៌ ។ ដោយតម្កល់ភាពផ្សេងៗគ្នានៃវប្បធម៌ឲ្យស្ថិតនៅជា "បេតិកភណ្ឌរួមនៃមនុស្សជាតិ" សេចក្ដីប្រកាសនេះ បានទទួលស្គាល់ភាពចាំបាច់ក្នុងការធានាឲ្យបាននូវភាពស៊ីសង្វាក់គ្នាមួយ រវាងបុគ្គល និងក្រុមមនុស្ស ដែលមានប្រភពវប្បធម៌ផ្សេងៗគ្នាផង និងការពារសមត្ថភាពបង្កើតថ្មី តាមរយៈទម្រង់រូបី និងអរូបីនៃវប្បធម៌។

## ៥ ហេតុអ្វីក៏អនុសញ្ញាមិនចាត់ចែងភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ជាលក្ខណៈរួម?

អនុសញ្ញាគិតគូរតែត្រឹមទិដ្ឋភាពនៃចំណោទបញ្ហាដែលកំណត់ឡើងដោយសេចក្ដីប្រកាសនៅឆ្នាំ២០០១ នៅក្នុងមាត្រា៨(ទ្រព្យសម្បត្តិសេវាកម្មវប្បធម៌ទំនិញដែលមិនដូចទំនិញដទៃ)មាត្រា៩(នយោបាយវប្បធម៌កាតាលីករនៃការបង្កើតថ្មី) មាត្រា១០ (ពង្រឹងសមត្ថភាពបង្កើតថ្មី និងការផ្សព្វផ្សាយនៅលើពិភពលោក) មាត្រា១១ (ពង្រឹងកិច្ចសហការជាដៃគូរវាងផ្នែករដ្ឋ និងផ្នែកឯកជន និងសង្គមស៊ីវិល)។ សូមកុំភ្លេចថាលក្ខណៈដទៃទៀតនៃភាពផ្សេងៗគ្នានៃវប្បធម៌ត្រូវបានការពារដោយអនុសញ្ញាអន្តរជាតិចំនួន៦ ដែលត្រូវបានតាក់តែងឡើងជាបន្តបន្ទាប់ដោយអង្គការយូណេស្កូ គឺអនុសញ្ញាសាកលស្ដីពីសិទ្ធិអ្នកនិពន្ធ (ឆ្នាំ១៩៥២ ធ្វើវិសោធនកម្មនៅឆ្នាំ១៩៧១ អនុសញ្ញាស្ដីពីការការពារនិងលើកស្ទួយសម្បត្តិវប្បធម៌ក្នុងករណីជម្លោះប្រដាប់អាវុធ (ពិធីការទី១ធ្វើឡើងនៅឆ្នាំ១៩៥៤ ពិធីការទី២ធ្វើឡើងនៅឆ្នាំ១៩៩៩), អនុសញ្ញាទាក់ទិននឹងការចាត់វិធានការដើម្បីហាមប្រាម និងឃាត់ឃាំងការនាំចូល ការនាំចេញ និងការបញ្ជូនសម្បត្តិវប្បធម៌ដែលជាកម្មសិទ្ធិមិនស្របច្បាប់ (ឆ្នាំ១៩៧០) អនុសញ្ញាទាក់ទិននឹងការការពារបេតិកភណ្ឌពិភពលោកទាំងបេតិកភណ្ឌវប្បធម៌និងធម្មជាតិ (ឆ្នាំ១៩៧២) អនុសញ្ញាស្ដីពីការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក (ឆ្នាំ២០០១) អនុសញ្ញាស្ដីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី (ឆ្នាំ២០០៣)។

បច្ចុប្បន្ននេះ លិខិតុបករណ៍ចំនួនបីគឺជាសសរស្ដម្ភនៃការអភិរក្ស និងការលើកស្ទួយភាពផ្សេងៗគ្នានៃការបង្កើតថ្មី: អនុសញ្ញានៅឆ្នាំ១៩៧២ ដែលទាក់ទិនទៅនឹងបេតិកភណ្ឌពិភពលោក វប្បធម៌ និងអរូបី និងអនុសញ្ញានៅឆ្នាំ២០០៥ ស្ដីពីការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។អនុសញ្ញាចុងក្រោយនេះ ខុសពីអនុសញ្ញាពីរខាងដើម ដែលធ្វើឡើងដើម្បីបេតិកភណ្ឌ គឺវាឧទ្ទិសជាពិសេសដល់ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដែលបានដាក់ផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងអាចទទួលបានតាមរយៈសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌។

## ៦ តើដំណាក់កាលអ្វីខ្លះដែលនាំឲ្យកើតមានការអនុម័តអនុសញ្ញា?

ការងាររៀបចំនៃការផ្ដើមធ្វើគម្រោងអនុសញ្ញាប្រើពេលវេលាអស់២ឆ្នាំ ។ ការធ្វើកិច្ចចរចាបានចាប់ផ្ដើមឡើង បន្ទាប់ពីបានអនុម័តសេចក្ដីសម្រេចលេខ 32C/34 ក្នុងសម័យប្រជុំលើកទី៣២ នៃមហាសន្និបាត (ខែតុលា ឆ្នាំ២០០៣) ។ អនុលោមតាមសេចក្ដីសម្រេចខាងលើនេះ និងទៅតាមនីតិវិធីដែលចូលជាធរមានក្នុងអង្គការយូណេស្កូ ដើម្បីតាក់តែង និងអនុម័តលិខិតុបករណ៍អន្តរជាតិ លោកអគ្គនាយកបានប្រគល់ជូនអ្នកឯកទេសឯករាជ្យចំនួន១៥នាក់ នូវបេសកកម្មក្នុងការផ្ដើមគិតពិចារណា និងផ្ដល់ជូនលោកវិញនូវអនុសាសន៍ ដើម្បីធ្វើគម្រោងដំបូងនៃអនុសញ្ញា ស្ដីពីការការពារភាពផ្សេងៗគ្នានៃខ្លឹមសារវប្បធម៌ និងវិញ្ញត្តិសិល្បៈ។ ការប្រជុំបីលើកនៃអ្នកជំនាញការឯករាជ្យ អាចផ្ដល់លទ្ធភាពដល់ពួកគេក្នុងការតាក់តែងអត្ថបទយ៉ាងពិស្ដារ។

បន្ទាប់ពីកិច្ចប្រជុំនៅមក លោក កូជីរ៉ូ ម៉ាត់ស៊ូអ៊ូរ៉ា អគ្គនាយកនៃអង្គការយូណេស្កូ បានប្រគល់ជូនរដ្ឋសមាជិក នូវរបាយការណ៍ដំបូងមួយ ជាមួយនឹងគម្រោងដំបូងនៃអនុសញ្ញា នៅពាក់កណ្តាលខែកក្កដា ឆ្នាំ២០០៤ ដើម្បីប្រមូលនូវសេចក្តីអធិប្បាយ និងសេចក្តីសង្កេតជាលាយលក្ខណ៍អក្សរ នៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០០៤។ នៅក្នុងឱកាសនោះដែរ លោកបានពិភាក្សាជាមួយនឹងអង្គការរដ្ឋាភិបាលអន្តរជាតិដទៃទៀត ដូចជាអង្គការពាណិជ្ជកម្មពិភពលោក (OMC) សន្និសីទនៃអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងអភិវឌ្ឍន៍ (CNUCED) និងអង្គការពិភពលោកនៃកម្មសិទ្ធិបញ្ញា (OMPI) បានផ្តល់នូវសេចក្តីអធិប្បាយទៅលើគម្រោងដើមនៃអនុសញ្ញានៅ ខែវិច្ឆិកាឆ្នាំ២០០៤។

សម័យប្រជុំអន្តររដ្ឋាភិបាលទាំងបីនៃអ្នកជំនាញការបានប្រព្រឹត្តទៅរវាងខែកញ្ញាឆ្នាំ២០០៤ និងខែមិថុនា ឆ្នាំ២០០៥ ដើម្បីផ្តល់លទ្ធភាពដល់អ្នកតំណាងរដ្ឋសមាជិកនៃអង្គការយូណេស្កូ ក្នុងការតស៊ូមតិ និងកែលម្អអត្ថបទដែលគាត់តែងឡើងដោយក្រុមអ្នកជំនាញការឯករាជ្យ ។ ចំណែកឯកិច្ចប្រជុំនៃគណៈកម្មាធិការនិពន្ធ ដែលត្រូវបានបង្កើតឡើងកាលពីសម័យប្រជុំអន្តររដ្ឋាភិបាលលើកទី១នោះ អាចឲ្យគេបញ្ចប់ការនិពន្ធអត្ថបទគម្រោងដើមនៃអនុសញ្ញា។ ដំណាក់កាលផ្សេងៗទាំងនេះ បាននាំឆ្ពោះទៅរកការអនុម័តអនុសញ្ញាស្តីពីការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ នៅ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ដោយមហាសន្និបាត នាសម័យប្រជុំលើកទី៣៣ (រដ្ឋចំនួន១៣៣បានបោះឆ្នោតយល់ស្រប រដ្ឋចំនួន២បានបោះឆ្នោតជំទាស់ រដ្ឋចំនួន៤បានបោះឆ្នោតអនុប្បវាទ)។

ដើម្បីទទួលបានព័ត៌មានបន្ថែមស្តីពីនីតិវិធី សូមចូលអានក្នុងវេបសាយ៖ www.unesco.org/culture/diversite/convention

បន្ទាប់ពីកិច្ចប្រជុំនៅមក លោក កូជីរ៉ូ ម៉ាត់ស៊ូអ៊ូរ៉ា អគ្គនាយកនៃអង្គការយូណេស្កូ បានប្រគល់ជូនរដ្ឋសមាជិកនូវរបាយការណ៍ដំបូងមួយ ជាមួយនឹងគម្រោងដំបូងនៃអនុសញ្ញា នៅពាក់កណ្ដាលខែកក្កដា ឆ្នាំ២០០៤ ដើម្បីប្រមូលនូវសេចក្ដីអធិប្បាយ និងសេចក្ដីសង្កេតជាលាយលក្ខណ៍អក្សរ នៅពាក់កណ្ដាលខែវិច្ឆិកា ឆ្នាំ២០០៤។ នៅក្នុងឱកាសនោះដែរ លោកបានពិភាក្សាជាមួយនឹងអង្គការរដ្ឋាភិបាលអន្តរជាតិដទៃទៀត ដូចជាអង្គការពាណិជ្ជកម្មពិភពលោក (OMC) សន្និសីទនៃអង្គការសហប្រជាជាតិស្ដីពីពាណិជ្ជកម្មនិងអភិវឌ្ឍន៍ (CNUCED) និងអង្គការពិភពលោកនៃកម្មសិទ្ធិបញ្ញា (OMPI) បានផ្ដល់នូវសេចក្ដីអធិប្បាយទៅលើគម្រោងដើមនៃអនុសញ្ញានៅ ខែវិច្ឆិកាឆ្នាំ២០០៤។

សម័យប្រជុំអន្តររដ្ឋាភិបាលទាំងបីនៃអ្នកជំនាញការបានប្រព្រឹត្តទៅរវាងខែកញ្ញាឆ្នាំ២០០៤ និងខែមិថុនា ឆ្នាំ២០០៥ ដើម្បីផ្ដល់លទ្ធភាពដល់អ្នកតំណាងរដ្ឋសមាជិកនៃអង្គការយូណេស្កូ ក្នុងការតស៊ូមតិ និងកែលម្អអត្ថបទដែលគាត់តែងឡើងដោយក្រុមអ្នកជំនាញការឯករាជ្យ ។ ចំណែកឯកិច្ចប្រជុំនៃគណៈកម្មាធិការនិពន្ធ ដែលត្រូវបានបង្កើតឡើងកាលពីសម័យប្រជុំអន្តររដ្ឋាភិបាលលើកទី១នោះ អាចឲ្យគេបញ្ចប់ការនិពន្ធអត្ថបទគម្រោងដើមនៃអនុសញ្ញា។ ដំណាក់កាលផ្សេងៗទាំងនេះ បាននាំឆ្ពោះទៅរកការអនុម័តអនុសញ្ញាស្ដីពីការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ នៅ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ដោយមហាសន្និបាត នាសម័យប្រជុំលើកទី៣៣ (រដ្ឋចំនួន១៣៣បានបោះឆ្នោតយល់ស្រប រដ្ឋចំនួន២បានបោះឆ្នោតជំទាស់ រដ្ឋចំនួន៤បានបោះឆ្នោតអនុប្បវាទ)។

ដើម្បីទទួលបានព័ត៌មានបន្ថែមស្ដីពីនីតិវិធី សូមចូលអានក្នុងវេបសាយ៖ www.unesco.org/culture/diversite/convention

## ៩ តើសិទ្ធិអ្វីខ្លះដែលអនុសញ្ញាទទួលស្គាល់សម្រាប់រដ្ឋភាគី ?

អនុសញ្ញាទទួលស្គាល់ចំពោះរដ្ឋភាគី នូវសិទ្ធិជាអធិបតេយ្យរបស់ខ្លួន ក្នុងការគាក់តែង និងការអនុវត្តន៍នយោបាយវប្បធម៌របស់ខ្លួន និងអនុម័តវិធានការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដោយអនុលោមទៅ តាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ទៅនឹងគោលការណ៍ច្បាប់អន្តរជាតិ និងលិខិតុបករណ៍ដែលគេទទួលស្គាល់ជាសាកលថាគោរពសិទ្ធិមនុស្ស (មាត្រា៥)។ អនុសញ្ញាបានផ្តល់នូវបញ្ជីចង្អុលបង្ហាញពីវិធានការដែលរដ្ឋភាគីអាចអនុម័តក្នុងន័យនោះ (មាត្រា៦):

- វិធានការបទបញ្ញត្តិសំដៅការពារនិងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

- វិធានការដែលផ្តល់ឱកាសដល់សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ដែលមានប្រភពមកពីដែនដី ដើម្បីទទួលបាននូវតួនាទីរបស់ខ្លួនក្នុងបណ្តាសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ដែលមានស្រាប់។

- វិធានការដែលផ្តល់ដល់ឧស្សាហកម្មវប្បធម៌ជាតិឯករាជ និងវិស័យមិនផ្លូវការ នូវការទទួលបានមធ្យោបាយ ផលិតកម្ម ផ្សព្វផ្សាយ និងចែកចាយដ៏ពិតប្រាកដ។

- វិធានការដែលផ្តល់ជូននូវការឧបត្ថម្ភថវិកាសាធារណៈ។

- វិធានការដែលលើកទឹកចិត្តដល់រាល់បំពេញសកម្មភាពផ្នែកវប្បធម៌ (ស្ថាប័នរដ្ឋ និងឯកជន សិល្បករ និងអ្នកមានអាជីពផ្នែកវប្បធម៌ អង្គការដែលគ្មានគោលដៅស្វែងរកកម្រៃ) ឲ្យលើកស្ទួយការផ្លាស់ប្តូរគំនិតដោយបើកទូលាយ និងការផ្សព្វផ្សាយគំនិត និងវិញ្ញត្តិវប្បធម៌ដោយសេរី។
- វិធានការដែលគាំទ្រដល់ស្ថាប័ននៃសេវាកម្មសាធារណៈ។

- វិធានការដែលលើកទឹកចិត្ត និងគាំពារសិល្បករ និងអ្នកប្រឌិតបង្កើតថ្មី។

- វិធានការដែលធានានូវការលើកស្ទួយភាពផ្សេងៗគ្នានៃសារព័ត៌មាន ជាពិសេសគឺការផ្សាយវិទ្យុដែលជាសេវាកម្មសាធារណៈ។

ទោះជាយ៉ាងណា ការបំពេញសិទ្ធិនេះ ត្រូវធ្វើឡើងដោយអនុលោមទៅតាមបទបញ្ញត្តិនៃអនុសញ្ញាជាពិសេសទៅតាមគោលបំណង និងគោលការណ៍នៃអនុសញ្ញា (សូមមើលមាត្រា៧ និង១២)។

ក្រៅពីនោះ អនុសញ្ញាអាចឲ្យរដ្ឋភាគីសង្កេតមើលវត្តមាននៃស្ថានភាពពិសេស ដែលវិញ្ញត្តិវប្បធម៌នៅលើដែនដីរបស់ពួកគេអាចជួបហានិភ័យនៃការផុតរលត់ ជួបការគំរាមធ្ងន់ធ្ងរ ឬតម្រូវឲ្យមានការអភិរក្សជាបន្ទាន់ ទោះជាតាមរបៀបណាក៏ដោយ។ អនុសញ្ញាអាចឲ្យគេចាត់វិធានការសមស្របគ្រប់បែបយ៉ាងដើម្បីការពារ និងរក្សាវិញ្ញត្តិវប្បធម៌ក្នុងស្ថានភាពដូចជម្រាបជូនខាងលើនោះ។

## ១០ តើកាតព្វកិច្ចអ្វីខ្លះដែលអនុសញ្ញាដាក់ជូនរដ្ឋភាគី?

ទន្ទឹមនឹងសិទ្ធិដែលគេទទួលស្គាល់ រដ្ឋភាគីសន្យាចំពោះអនុសញ្ញាថាត្រូវការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ទាំងនៅលើទឹកដីរបស់ខ្លួន ក៏ដូចជានៅលើឆាកអន្តរជាតិ អនុលោមទៅតាមបទបញ្ញត្តិនៃអនុសញ្ញា (មាត្រា៥)។

ការសន្យាមួយក្នុងចំណោមការសន្យាជាច្រើនគឺត្រូវលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌(មាត្រា៧)។ រដ្ឋភាគីត្រូវធ្វើយ៉ាងណាសម្រួលដល់បរិយាកាសជុំវិញ ដែលអាចឲ្យបុគ្គល និងក្រុមមនុស្សបង្កើត ផលិត ផ្សព្វផ្សាយ និងចែកចាយវិញ្ញត្តិវប្បធម៌របស់ខ្លួន និងអាចទទួលយកអ្វីៗទាំងនោះ និងអាចទទួលយករាល់វិញ្ញត្តិវប្បធម៌នៃពិភពលោកទាំងមូល។ រដ្ឋភាគីសន្យាថាចែករំលែកព័ត៌មាន និងធានានូវតម្លាភាព (មាត្រា៩)។ ការសន្យាទៅលើតម្លាភាពនេះ ត្រូវស្តែងឡើងតាមការរយៈការប្រគល់របាយការណ៍ជូនអង្គការយូណេស្កូ រាល់បួនឆ្នាំម្តង ដែលជាការបូកសរុបរាល់វិធានការដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ទាំងនៅថ្នាក់ជាតិ ក៏ដូចជានៅលើឆាកអន្តរជាតិ។ ការអប់រំ និងការបំផុសសាធារណជនក៏ជាការសន្យាមួយរបស់រដ្ឋភាគីផងដែរ (មាត្រា១០)។ ដើម្បីកិច្ចការនោះ រដ្ឋភាគីត្រូវសម្រួល និងពង្រីកឲ្យយល់ពីសារៈសំខាន់នៃការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ និងសហការជាមួយគ្នា និងជាមួយអង្គការអន្តរជាតិ និងអង្គការក្នុងតំបន់។ ទីបញ្ចប់ រដ្ឋភាគីត្រូវធានារ៉ាប់រងកាតព្វកិច្ចនៅថ្នាក់ជាតិទាក់ទងទៅនឹងសហប្រតិបត្តិការរវាងប្រទេសនានា (សំណួរទី១១) ព្រមទាំងតួនាទីដែលសង្គមស៊ីវិលត្រូវបំពេញ (សំណួរ១៩)។

## ១១ តើតួនាទីនៃសហប្រតិបត្តិការអន្តរជាតិនៅក្នុងអនុសញ្ញាមានដូចម្តេចខ្លះ?

អនុសញ្ញាផ្តល់សារៈសំខាន់យ៉ាងខ្លាំងដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលនៅក្នុងនោះការលើកស្ទួយត្រូវស្ថិតនៅក្នុងចំណោមកាតព្វកិច្ចនៃរដ្ឋភាគី (មាត្រ១២និង១៤)។ សាមគ្គីភាពអន្តរជាតិគឺជាការឆ្លើយតបយ៉ាងជាក់ស្តែងទៅនឹងអសមភាពរវាងរដ្ឋចំពោះមធ្យោបាយប្រើប្រាស់សម្រាប់វិញ្ញត្តិវប្បធម៌។មធ្យោបាយទាំងនោះបង្ហាញពីសកម្មភាពគោលជាក់ស្តែង ដែលផ្អែកទៅលើភាពជាដៃគូ។ វាសំដៅបង្កើនសមត្ថភាពបង្កើត ផលិត ផ្សព្វផ្សាយ និងចែកចាយវិញ្ញត្តិវប្បធម៌ ធ្វើយ៉ាងណាឲ្យរដ្ឋភាគី ជាពិសេសរដ្ឋណាដែលវិញ្ញត្តិវប្បធម៌កំពុងរងគ្រោះថ្នាក់ និង/ឬ ដែលគ្មានមធ្យោបាយគ្រប់គ្រាន់ក្នុងការធានាការការពារ និងការលើកស្ទួយ អាចពឹងផ្អែកទៅលើសាមគ្គីភាពអន្តរជាតិ។

ជាឧទាហរណ៍ តាមរយៈចំណាប់អារម្មណ៍ជាពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍ (មាត្រា១៦) និងតាមរយៈឆន្ទៈជួយគ្នាទៅវិញទៅមក ក្នុងស្ថានភាពគំរាមធ្ងន់ធ្ងរដល់វិញ្ញត្តិវប្បធម៌ (មាត្រា១៧) សាមគ្គីភាពខាងលើនេះមានគោលបំណងកាត់បន្ថយឲ្យបានជាក់ស្តែងនូវហានិភ័យនៃភាពចម្លែកខុសគ្នា ដែលអាចបង្កឡើងដោយដំណើរការសាកលភាវូបនីយកម្ម ទៅលើភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។

# ១២ តើគោលការណ៍ចង្អុលទិសសកម្មភាពនៃរដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញាមានដូចម្តេចខ្លះ?

សិទ្ធិទាំងឡាយដែលទទួលស្គាល់ចំពោះរដ្ឋភាគី ក៏ដូចជាការសន្យានៃប្រទេសទាំងនោះដែរ មិនមែនសុទ្ធតែត្រូវអនុវត្តបែបណាក៏បាននោះឡើយ ។ រដ្ឋភាគីត្រូវទទួលសិទ្ធិ និងធានាារាប់រងកាតព្វកិច្ចរបស់ខ្លួន អនុលោមទៅតាមបទបញ្ញត្តិនៃអនុសញ្ញា ជាពិសេសដោយគោរពទៅតាមគោលបំណងនិងគោលការណ៍នៃអនុសញ្ញា។ ចំពោះចំណុចនេះ អនុសញ្ញាបានរៀបរាប់នៅក្នុងមាត្រាទី២ នូវគោលការណ៍ដៅទិសមួយចំនួន ដែលដឹកនាំរដ្ឋភាគីក្នុងការបកស្រាយ និងការអនុវត្តន៍អនុសញ្ញា។ ក្នុងចំណោមគោលការណ៍ទាំងនោះ មានការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដូចជាសេរីភាពបញ្ចេញមតិ ផ្តល់ព័ត៌មាន និងក្នុងទំនាក់ទំនង។ គោលការណ៍បើកទូលាយ និងលំនឹងជាគោលការណ៍គ្រឹះ ចាប់ពីពេលដែលវាបញ្ជាក់ប្រាប់ថារដ្ឋភាគីទាំងឡាយត្រូវធានាឲ្យបានខ្ជាប់ខ្ជួន និងសមស្របក្នុងការលើកស្ទួយការបើកទូលាយទៅរកវប្បធម៌ពិភពលោក តាមរយៈការអនុម័តនយោបាយនិងវិធានការរបស់ខ្លួន។ គោលការណ៍បើកទូលាយនោះឯង គឺជាការធានាឲ្យមាននូវភាពផ្សេងៗគ្នានៃវប្បធម៌។ ការគោរពដល់គោលការណ៍ស្មើភាពចំពោះគ្រប់វប្បធម៌ គឺជាការដែលមិនអាចចៀសផុតឡើយ ក្នុងការគាក់តែងនយោបាយ និងវិធានការ ដោយគិតទៅដល់វិញ្ញត្តិវប្បធម៌នៃជនជាតិភាគតិច និងអ្នកស្រុកជនជាតិដើម។ ការគោរពដល់គោលការណ៍ទទួលបានប្រកបដោយសមធម៌ ដែលធានាដល់បុគ្គលម្នាក់ៗឲ្យទទួលបាន និងរីករាយចំពោះវិញ្ញត្តិវប្បធម៌សំបូរបែប និងប្លែកៗគ្នា ក៏ជាកូនសោគន្លឹះមួយ សម្រាប់ការចែករំលែកភាពផ្សេងៗគ្នានៃវប្បធម៌ និងការធ្វើឲ្យមាននិរន្តរភាព។ ទីបញ្ចប់ គេគប្បីលើកឡើងពីគោលការណ៍បំពេញបន្ថែមនៃទិដ្ឋភាពសេដ្ឋកិច្ច និងវប្បធម៌ទៅលើការអភិវឌ្ឍ និងកិច្ចអភិវឌ្ឍជានិរន្តរភាព ដែលអនុសញ្ញាផ្តល់នូវតួនាទីដ៏សំខាន់មួយ។

# ដំណើរការ

## ១៣ តើអនុសញ្ញានឹងចូលជាធរមាននៅពេលណា?

អនុសញ្ញានឹងចូលជាធរមានបីខែបន្ទាប់ពីថ្ងៃតម្កល់លិខិតុបករណ៍ទី៣០នៃការធ្វើសច្ចាប័នយល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ចំពោះរដ្ឋ ឬអង្គការសេដ្ឋកិច្ចតំបន់ ដែលបានតម្កល់លិខិតុបករណ៍នៃការធ្វើសច្ចាប័នយល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិករបស់ខ្លួនក្នុងកាលបរិច្ឆេទនោះ។ ចំពោះរដ្ឋភាគីដទៃទៀត អនុសញ្ញា នឹងចូលជាធរមានបីខែបន្ទាប់ពីថ្ងៃតម្កល់លិខិតុបករណ៍ទី៣០នៃការផ្តល់សច្ចាប័នយល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក (មាត្រា២៩)។

## ១៤ តើត្រូវប្រើនីតិវិធីបែបណាដើម្បីផ្តល់សច្ចាប័នដល់អនុសញ្ញា?

"ការផ្តល់សច្ចាប័ន" មានន័យថាជាសកម្មភាពអន្តរជាតិ តាមរយៈសកម្មភាពទាំងនោះ រដ្ឋឬអង្គការសេដ្ឋកិច្ចតំបន់អះអាងពីការយល់ព្រមរបស់ខ្លួន ថាត្រូវមានទំនាក់ទំនងនឹងគ្នា តាមរយៈកតិកាសញ្ញាមួយ។ ដូច្នេះ អនុសញ្ញាត្រូវគោរពតាមការឲ្យសច្ចាប័នយល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិកនៃរដ្ឋសមាជិករបស់អង្គការយូណេស្កូ។ លិខិតុបករណ៍របស់រដ្ឋទាំងនោះ នឹងត្រូវប្រគល់ជូនអគ្គនាយកនៃអង្គការយូណេស្កូព្រមទាំងអង្គការសេដ្ឋកិច្ចតំបន់ (មាត្រា២៧)។

ជាឧទាហរណ៍ រដ្ឋមួយ ឬអង្គការសេដ្ឋកិច្ចតំបន់មួយ ចង់ក្លាយទៅជាភាគីមួយនៃអនុសញ្ញា ត្រូវផ្តល់សច្ចាប័នចំពោះអនុសញ្ញានោះ។ នីតិវិធីផ្ទៃក្នុងដែលត្រូវបំពេញរហូតដល់ពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នជូនអគ្គនាយកនៃអង្គការយូណេស្កូ មានភាពខុសៗគ្នាយ៉ាងខ្លាំង ទាំងរយៈពេល ទាំងរបៀបអនុវត្ត។ នីតិវិធីនោះមានលក្ខណៈដោយឡែកៗពីគ្នាចំពោះរដ្ឋនីមួយៗ ឬអង្គការសេដ្ឋកិច្ចតំបន់នីមួយៗ។

គំរូលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន (យល់ព្រមទទួលយក ឯកភាព ទៅតាមករណីផ្សេងៗគ្នា)៖

> លិខិតុបករណ៍នៃការឲ្យសច្ចាប័ន
>
> យើងខ្ញុំជា... (ឈ្មោះប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬរដ្ឋមន្ត្រី ក្រសួងការបរទេស)... នៃ... (ឈ្មោះប្រទេស) បានឃើញ និងពិនិត្យ... (ឈ្មោះអនុសញ្ញា)...
>
> បានយល់ព្រម និងយល់ព្រមចំពោះភាគីនីមួយៗ ដោយអនុលោមទៅតាមបទបញ្ញត្តិដែលមានចែងនៅក្នុងអនុសញ្ញា ចំពោះអាជ្ញាធរ ដែលបានប្រគល់ជូនយើងខ្ញុំ។ សូមប្រកាសផ្តល់សច្ចាប័នដល់អនុសញ្ញាខាងលើ ហើយសន្យាថានឹងអនុវត្តអនុសញ្ញានោះ ដោយឥតមានការបំពាន។
>
> អាស្រ័យហេតុនេះ យើងខ្ញុំសូមប្រគល់លិខិតុបករណ៍ ដោយមានបោះត្រា។
>
> ធ្វើនៅ... (ទីកន្លែង) ថ្ងៃទី... (កាលបរិច្ឆេទ)
>
> ហត្ថលេខា
>
> ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬរដ្ឋមន្ត្រីក្រសួងការបរទេស
>
> ប្រភព ៖http://portal.unesco.org/fr/ev.php-URL_ID=27541&URL_DO=DO_TOPIC&URL_SECTION=201.html

## ១៥ តើយន្តការនៃការតាមដានមានដូចម្តេចខ្លះ ?

អនុសញ្ញាបង្កើតអង្គការពីរដើម្បីដាក់ឲ្យដំណើរការ និងការត្រួតពិនិត្យអនុសញ្ញា ៖ សន្និសីទនៃរដ្ឋភាគី និងគណៈកម្មាធិការអន្តររដ្ឋាភិបាល ដើម្បីការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដោយមានការជួយជ្រោមជ្រែងពីលេខាធិការដ្ឋាននៃអង្គការយូណេស្កូ។ សម័យប្រជុំលើកទី១នៃសន្និសីទរដ្ឋភាគីក៏ដូចជាសន្និសីទនៃគណៈកម្មាធិការអន្តររដ្ឋាភិបាល ដើរតួនាទីចម្បងក្នុងការដាក់អនុសញ្ញាឲ្យដំណើរការប្រកបដោយប្រសិទ្ធិភាព។

## ១៦ តើអ្វីទៅជាសន្និសីទនៃរដ្ឋភាគី ? តើមុខងារនៃសន្និសីទនោះមានអ្វីខ្លះ ?

សន្និសីទនៃរដ្ឋភាគីជាការប្រមូលផ្តុំភាគីទាំងអស់នៃអនុសញ្ញា។ គឺជាមហាសន្និបាតពេញអង្គ និងអធិបតេយ្យនៃអនុសញ្ញា (មាត្រ២២)។ សន្និសីទនេះរៀបចំជាសម័យប្រជុំសាមញ្ញពីរឆ្នាំម្តង ហើយក្នុងករណីចាំបាច់ រៀបចំជាសម័យប្រជុំវិសាមញ្ញ។ មុខងារនៃសន្និសីទមានដូចតទៅ ៖ ជ្រើសរើសសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាល, យល់ព្រមលើសារាចរប្រតិបត្តិដែលរៀបចំឡើងដោយគណៈកម្មាធិការដើម្បីគោរព និងអនុវត្តអនុសញ្ញា, និងពិនិត្យមើលរបាយការណ៍នៃរដ្ឋភាគីស្តីពីវិធានការដែលធ្វើឡើងដោយរដ្ឋទាំងនោះ ទាក់ទិននឹងអនុសញ្ញា (មាត្រា១៨.៤ និង២២.៤ខ)។ សន្និសីទនៃរដ្ឋភាគីអាចចាត់វិធានការដទៃទៀតដែរ ដែលគេគិតថាចាំបាច់ដើម្បីលើកស្ទួយគោលបំណងនៃអនុសញ្ញា។ លើសពីនោះ សន្និសីទនៃរដ្ឋភាគីយល់ព្រមលើបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការ និងមូលដ្ឋាននៃទិសដៅទៅលើការប្រើប្រាស់ប្រភពមូលនិធិអន្តរជាតិដើម្បីភាពផ្សេងៗគ្នានៃវប្បធម៌។

## ១៧ តើអ្វីទៅជាគណៈកម្មាធិការអន្តររដ្ឋាភិបាល? តើមុខងារនៃគណៈកម្មាធិការនោះមានអ្វីខ្លះ ?

គណៈកម្មាធិការអន្តររដ្ឋាភិបាល គឺជាអង្គការមួយដែលទទួលបន្ទុកលើកស្ទួយគោលបំណងនៃអនុសញ្ញាព្រមទាំងលើកទឹកចិត្តនិងធានារ៉ាប់រងការតាមដានការដាក់អនុសញ្ញាឲ្យដំណើរការ(មាត្រា២៣)។សមាជិកនៃគណៈកម្មាធិការនេះត្រូវបានជ្រើសរើសដោយសន្និសីទនៃរដ្ឋភាគី សម្រាប់រយៈពេលបួនឆ្នាំ។

មុខងារនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលមានដូចតទៅ៖ រៀបចំសារាចរប្រតិបត្តិដែលទាក់ទិននឹងការដាក់ឲ្យដំណើរការ និងការអនុវត្តអនុសញ្ញា, បញ្ជូនដល់សន្និសីទនៃរដ្ឋភាគីនូវរបាយការណ៍អមដោយសេចក្តីសង្កេត និងសេចក្តីសង្ខេបពីខ្លឹមសារនៃរបាយការណ៍ទាំងនោះ សម្រេចចិត្តទៅលើការប្រើប្រាស់មូលនិធិអន្តរជាតិដើម្បីភាពផ្សេងៗគ្នានៃវប្បធម៌។ ជាមួយនឹងមុខងារទាំងនេះ គណៈកម្មាធិការក៏ជាអង្គការមួយដែលជាទីប្រឹក្សាផងដែរ ពីព្រោះថាគណៈកម្មាធិការនេះជាអ្នកផ្តល់អនុសាសន៍ ស្តីពីស្ថានភាពផ្សេងៗដែលជាការយកចិត្តទុកដាក់របស់អនុសញ្ញា ជាពិសេសនៅក្នុងករណីដែលវិញ្ញត្តិវប្បធម៌ទទួលរងការបាត់បង់ ទទួលការគំរាមធ្ងន់ធ្ងរ ឬតម្រូវឲ្យមានការអភិរក្សជាបន្ទាន់ (មាត្រ៨ និង២៣.៦ឃ)។ ម៉្យាងទៀត គណៈកម្មាធិការអន្តររដ្ឋាភិបាលអនុវត្តនីតិវិធី និងយន្តការពិគ្រោះយោបល់ផ្សេងៗទៀតនៅលើឆាកអន្តរជាតិ ដើម្បីលើកកម្ពស់គោលបំណង និងគោលការណ៍នៃអនុសញ្ញា។

## ១៨ តើមុខងារនៃលេខាធិការដ្ឋាននៃអង្គការយូណេស្កូមានអ្វីខ្លះ ?

លេខាធិការដ្ឋាននៃអង្គការយូណេស្កូ ជួយដល់សន្និសីទនៃរដ្ឋភាគី និងគណៈកម្មាធិការអន្តររដ្ឋាភិបាល ក្នុងការរៀបចំកិច្ចប្រជុំ និងរៀបចំឯកសារ (មាត្រា២៤)។ លេខាធិការដ្ឋានក៏ជួយផងដែរដល់អង្គការនានានៃអនុសញ្ញា ក្នុងការអនុវត្តសេចក្ដីសម្រេចចិត្ត និងធ្វើរបាយការណ៍ទៅលើអង្គប្រជុំ។

ម្យ៉ាងទៀតអាស្រ័យដោយយន្តការដែលមានស្រាប់នៅក្នុងលេខាធិការដ្ឋានដូចជាវិទ្យាស្ថានស្ថិតិអង្គការយូណេស្កូនឹងសម្រួលដល់ការប្រមូល វិភាគ និងផ្សព្វផ្សាយព័ត៌មាន ស្ថិតិ និងការអនុវត្តឲ្យបានប្រសើរជាងមុនទៅលើភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។ លើសពីនោះទៀត អង្គការយូណេស្កូនឹងបង្កើត និងធ្វើបច្ចុប្បន្នភាពបណ្ដាទិន្នន័យទាក់ទងទៅនឹងផ្នែក និងអង្គការរដ្ឋាភិបាលផ្សេងៗ ដែលមានលក្ខណៈឯកជន និងមិនគិតផលចំណេញ ហើយដែលបំពេញការងារក្នុងវិស័យវិញ្ញត្តិវប្បធម៌ (មាត្រា១៩)។

## ១៩ តើតួនាទីនៃសង្គមស៊ីវិលក្នុងការអនុវត្តន៍អនុសញ្ញាមានដូចម្ដេចខ្លះ ?

សង្គមស៊ីវិលមិនត្រឹមតែជាអ្នកទទួលអត្ថប្រយោជន៍ប៉ុណ្ណោះទេ តែក៏ជាដៃគូក្នុងការអនុវត្តន៍អនុសញ្ញាផងដែរ។ អង្គការក្រៅរដ្ឋាភិបាល ដែលតំណាងឲ្យអ្នកមានវិជ្ជាជីវៈផ្នែកវប្បធម៌ជាដើម បានចូលរួមយ៉ាងសកម្ម ក្នុងការតាក់តែងអនុសញ្ញា។ ដូច្នេះ វាជាការសំខាន់ណាស់ដែលសង្គមស៊ីវិលត្រូវចូលរួម ចាប់ពីពេលនេះតទៅ នៅក្នុងការអនុវត្តន៍អនុសញ្ញា។ ក្នុងសកម្មភាពនេះ អនុសញ្ញាបានទទួលស្គាល់យ៉ាងជាក់ច្បាស់ពី "តួនាទីដ៏សំខាន់នៃសង្គមស៊ីវិល ក្នុងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ " ហើយអំពាវនាវដល់រដ្ឋភាគីឲ្យពង្រឹងភាពជាដៃគូជាមួយនឹងសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន ក្នុងការបន្តបំពេញគោលបំណងនៃអនុសញ្ញា (មាត្រា១១, ១២.គ, ១២.ឃ)។

ម្យ៉ាងវិញទៀត គណៈកម្មាធិការអន្តររដ្ឋាភិបាលក៏អាចអញ្ជើញអង្គការរដ្ឋ និងឯកជននៅក្នុងខណៈណាមួយក៏បាន ហើយថែមទាំងអាចអញ្ជើញរូបវន្តបុគ្គល ឲ្យចូលរួមប្រជុំដើម្បីពិគ្រោះយោបល់ស្ដីពីចំណោទបញ្ហាពិសេសផ្សេងៗ (មាត្រា២៣.៧)។

## ២០ តើអ្វីទៅជាមូលនិធិអន្តរជាតិដើម្បីភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ?

មូលនិធិអន្តរជាតិដើម្បីភាពផ្សេងៗគ្នានៃវប្បធម៌ ដែលបានគ្រោងទុកនៅក្នុងអនុសញ្ញា (មាត្រា១៨) គឺជាមូលនិធិតម្កល់ ដែលទុកសម្រាប់រដ្ឋភាគីយកទៅប្រើប្រាស់ ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដើម្បីជួយភាគីទាំងនោះឲ្យគោរព និងអនុវត្តអនុសញ្ញា។ ការប្រើប្រាស់ប្រភពមូលនិធិត្រូវសម្រេចឡើងដោយគណៈកម្មាធិការអន្តររដ្ឋាភិបាល ស្របតាមទិសដៅដែលផ្ដល់ជូនដោយសន្និសីទនៃរដ្ឋភាគី។

ប្រភពមូលនិធិនឹងត្រូវបង្កើតឡើងតាមរយៈការចូលរួមដោយស្ម័គ្រចិត្តនៃរដ្ឋភាគី អំណោយ ឬមត៌កដែលអាចធ្វើឡើងដោយរដ្ឋដទៃទៀត អង្គការតំបន់ឬអន្តរជាតិដទៃទៀត អង្គការរដ្ឋឬឯកជន និងបុគ្គលផ្សេងៗ។ មូលនិធិនេះអាចទទួលបានពីការរៃអង្គាស និងពីចំណូលទទួលបានពីសម្ដែងទស្សនីយភាពដែលរៀបចំឡើងក្នុងគោលដៅនោះ។

## ២១ តើយន្តការនៃការដោះស្រាយជម្លោះដំណើរការយ៉ាងដូចម្តេច ?

យន្តការនៃការដោះស្រាយជម្លោះមានគ្រោងឡើង ដើម្បីលើកឡើងពីការខ្វែងគំនិតគ្នាជាយថាហេតុ រវាងរដ្ឋភាគីនានានៃអនុសញ្ញា ស្តីពីការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិក្នុងមួយចំនួន ឬគោលការណ៍ទាក់ទិននឹងអនុសញ្ញា (មាត្រា២៥)។ យន្តការនេះតម្រូវជាដំបូងឲ្យរដ្ឋភាគីធ្វើការចរចា រួចអនុញ្ញាតឲ្យពួកគេធ្វើអាជ្ញាកណ្តាល និងធ្វើការផ្សះផ្សារគ្នា។

ប្រសិនបើភាគីមិនអាចចុះសម្រុងគ្នា ចំពោះដំណោះស្រាយទៅលើជម្លោះ ដោយមធ្យោបាយមួយឬច្រើនទេនោះ ភាគីទាំងនោះអាចចាប់ផ្តើមធ្វើការផ្សះផ្សារ។ នីតិវិធីនេះអាចត្រូវស្នើឡើងដោយសំណូមពររបស់រដ្ឋភាគីតែមួយគត់ ក្នុងចំណោមភាគីជម្លោះ។ ប៉ុន្តែភាគីនានាអាចជ្រើសរើសមិនទទួលស្គាល់នីតិវិធីនេះ តាមរយៈសេចក្តីប្រកាសដ៏ងាយមួយនៅក្នុងខណៈផ្តល់សច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក។ ក្នុងន័យនេះ អនុសញ្ញាប្រគល់យន្តការផ្ទាល់របស់ខ្លួនសម្រាប់រដ្ឋភាគីទាំងឡាយ ដែលចង់ប្រើប្រាស់ដើម្បីធ្វើឲ្យបទបញ្ញាមានប្រសិទ្ធិភាព ក្នុងករណីមានជម្លោះជាមួយនឹងភាគីដទៃទៀតដែលព្រមទទួលយកយន្តការនេះដែរ។

ទីបញ្ចប់ យន្តការនៃការដោះស្រាយជម្លោះសម្រាប់តែរដ្ឋភាគីនៃអនុសញ្ញា គឺថារដ្ឋភាគីទាំងនោះគឺមានតែរដ្ឋ ឬអង្គការសេដ្ឋកិច្ចតំបន់តែប៉ុណ្ណោះ។ ដូច្នេះ ទោះបីជាអនុសញ្ញាទទួលស្គាល់តួនាទីនៃសង្គមស៊ីវិល និងវិស័យឯកជនក្នុងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ យន្តការនៃការដោះស្រាយជម្លោះ មិនមែនសម្រាប់អ្នកបំពេញការងារផ្សេងពីរដ្ឋភាគីដទៃទៀត ក្រៅពីរដ្ឋភាគីនៃអនុសញ្ញាឡើយ (ដូចជាសហគ្រាសជាដើម) ពីព្រោះរដ្ឋភាគីទាំងនោះមិនទាក់ទងតាមផ្លូវគតិយុត្តិទៅ នឹងអនុសញ្ញាឡើយ។

## ២២ តើអនុសញ្ញានេះមានកំណត់ទំនាក់ទំនងជាមួយនឹង លិខិតុបករណ៍គតិយុត្តិអន្តរជាតិផ្សេងៗទៀតដែរឬទេ ?

អនុសញ្ញាជាលិខិតុបករណ៍គតិយុត្តិអន្តរជាតិ ដែលលើកឡើងពីភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។ ថ្វីត្បិតតែដែនអនុវត្តរបស់វា ស្ថិតនៅក្នុងក្របខណ្ឌនៃ "នយោបាយ និងវិធានការដែលអនុម័តដោយរដ្ឋភាគីទាក់ទិននឹងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ " យ៉ាងណាក្តី (មាត្រា៣ សូមមើលសំណួរទី៨) តែការដាក់បទបញ្ញត្តិ អនុសញ្ញាឲ្យដំណើរការ អាចបង្ហាញពីសកម្មភាពទំនាក់ទំនងរវាងសិទ្ធិ និងកាតព្វកិច្ចនៃរដ្ឋភាគីដែលមាននៅក្នុងកតិកាសញ្ញាថ្មីនេះ រឺងសិទ្ធិ និងកាតព្វកិច្ចដែលចេញពីកិច្ចសន្យាអន្តរជាតិដទៃទៀត ដែលរដ្ឋភាគីចូលជាសមាជិក។

ចំពោះចំណុចនេះ អនុសញ្ញាបានកំណត់នៅក្នុងមាត្រា២០ ពីទំនាក់ទំនងរវាងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត និងបញ្ជាក់ទំនាក់ទំនងរវាងកតិកាសញ្ញាទាំងនោះ ក្នុងករណីមានការគងជាន់គ្នា រវាងសិទ្ធិ និងកាតព្វកិច្ច។ បើតាមមាត្រានោះ រដ្ឋភាគីត្រូវបំពេញដោយចិត្តស្មោះស្ម័គ្រ នូវកាតព្វកិច្ចដែលចេញមកពីអនុសញ្ញា ក៏ដូចជាកាតព្វកិច្ចដែលមកពីកតិកាសញ្ញាដទៃទៀតដែលរដ្ឋភាគីចូលជាសមាជិក ដោយឥតដាក់អនុសញ្ញាក្រោមរណបនៃកតិកាសញ្ញាដទៃទៀតឡើយ។ ក្នុងទិសដៅនេះ អនុសញ្ញាអំពាវនាវឲ្យរដ្ឋភាគីឲ្យលើកទឹកចិត្តដោយគាំទ្រគ្នាទៅវិញទៅមក រវាងអនុសញ្ញា និងកតិកាសញ្ញាដទៃទៀត។ អនុសញ្ញាក៏អំពាវនាវផងដែរឲ្យរដ្ឋភាគី គិតគូរដល់បទបញ្ញត្តិសមស្របនៃអនុសញ្ញា ក្នុងខណៈដែលរដ្ឋភាគីបកស្រាយ និងអនុវត្តកតិកាសញ្ញាដទៃទៀតដែលខ្លួនចូលជាសមាជិក ឬនៅពេលដែលរដ្ឋភាគីសន្យាថាបំពេញកាតព្វកិច្ចអន្តរជាតិដទៃទៀត។

# ២៣ តើអនុសញ្ញាមានទំនាក់ទំនងជាមួយលិខិតុបករណ៍អន្តរជាតិតាមរបៀបដូចម្តេចខ្លះ ?

មាត្រាទី២០ បញ្ជាក់ថា គ្មានអ្វីមួយនៅក្នុងអនុសញ្ញាដែលអាចផ្លាស់ប្តូរសិទ្ធិ និងកាតព្វកិច្ច នៃរដ្ឋភាគីក្នុងនាមនៃកតិកាសញ្ញាដទៃទៀត ដែលរដ្ឋភាគីទាំងនោះចូលជាសមាជិកឡើយ។ កតិកាសញ្ញាទាំងអស់សុទ្ធមានទិសដៅច្បាស់លាស់ ទោះជាកតិកាសញ្ញាទាំងនោះចូលជាធរមាន ឬនឹងចូលជាធរមាននៅថ្ងៃខាងមុខក៏ដោយ។

មាត្រាទី២០ឆ្លុះបញ្ចាំងដាយឥតបំភ្លេលនៃ្វគាលបំណាងមួយនអែនុសញ្ញាដលែសំដាទទួលស្គាល់នូវលក្ខណៈទ្វេ គឺលក្ខណៈសេដ្ឋកិច្ច និងវប្បធម៌នៃសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌។ រាល់ផ្នែកទាំងអស់នៃច្បាប់អន្តរជាតិ ដែលអាចមានសកម្មភាពទំនាក់ទំនងជាមួយនឹងការដាក់អនុសញ្ញាឲ្យដំណើរការសុទ្ធតែត្រូវបានគ្រោងទុក ក្នុងស្មារតីនៃការបំពេញបន្ថែម និងគាំទ្រគ្នាទៅវិញទៅមក។ ថ្វីត្បិតតែកតិកាសញ្ញាអន្តរជាតិទាំងអស់ សុទ្ធតែមានវត្ថុបំណងខុសៗគ្នាមែន តែវត្ថុបំណងទាំងនោះអាចត្រូវគេតាមដានប្រកបដោយភាពស៊ីសង្វាក់និងបំពេញបន្ថែម។

ទីបញ្ចប់ដីម្បីសម្រួលដល់ការព្រមព្រៀងគ្នានិងការសម្របសម្រួលរវាងលិខិតុបករណ៍គតិយុត្តិអន្តរជាតិរដ្ឋភាគីត្រូវសន្យាផងដែរថា នឹងលើកកម្ពស់វត្ថុបំណងនិងគោលការណ៍នៃអនុសញ្ញានៅក្នុងការពិគ្រោះយោបល់ដទៃទៀតហើយការពិគ្រោះយោបល់ដើម្បីកិច្ចការនោះត្រូវធ្វើឡើងរវាងផ្នែកអន្តរជាតិទាំងនោះ(មាត្រាទី២១)។ នេះជាទម្រង់មួយទៀតនៃការទទួលស្គាល់សកម្មភាពទំនាក់ទំនង ដែលអាចស្តែងឡើងរវាងអនុសញ្ញានិងកតិកាសញ្ញាអន្តរជាតិដទៃទៀតហើយរដ្ឋភាគីជាអ្នកទទួលបន្ទុកចាត់ចែង "ទំនាក់ទំនង" រវាងវេទិកាចរចាអន្តរជាតិនានា។

# សេចក្តីបញ្ជាក់

## ២៤ តើសារប្រយោជន៍ក្នុងការធ្វើសច្ចាប័នទៅលើអនុសញ្ញាមានដូចម្តេចខ្លះ ?

ចំណុចល្អនៃអនុសញ្ញាដែលស័ក្តិសមនឹងទទួលបានគឺការផ្តល់តួនាទីមួយដល់ការបង្កើតថ្មីនៅក្នុងសាកលភាវូបនីយកម្ម។ តាមរយៈបទបញ្ញត្តិទាំងនោះអនុសញ្ញាផ្តល់អត្ថប្រយោជន៍ជូនបុគ្គល និងសង្គមព្រោះអនុសញ្ញាធានាជូនអ្នកទាំងនោះនូវសេចក្តីសោមនស្សរីករាយ ក្នុងការទទួលបានភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ក្នុងស្មារតីបើកទូលាយ គុល្យភាព និងសេរីភាព ។

ក្នុងចំណោមអ្នកទទួលបានអត្ថប្រយោជន៍ យើងអាចរាប់បញ្ចូលមុនគេនូវប្រទេសដែលខ្វះសមត្ថភាពផលិត និងផ្សព្វផ្សាយវិញ្ញត្តិវប្បធម៌របស់ខ្លួន និងជាពិសេសប្រទេសកំពុងអភិវឌ្ឍ។ អនុសញ្ញាក៏មានចំណុចវិជ្ជមានផងដែរ ចំពោះសិល្បករ អ្នកមានវិជ្ជាជីវៈ និងអ្នកបំពេញការងារផ្នែកវប្បធម៌ គឺអ្នកទាំងឡាយណាដែលចូលរួមក្នុងដំណើរការបង្កើតថ្មី ផលិត និងផ្សព្វផ្សាយវិញ្ញត្តិវប្បធម៌ ទោះជាស្ថិតក្នុងលក្ខណៈបុគ្គល ឬជាក្រុមក៏ដោយ។ អ្នកទទួលបានអត្ថប្រយោជន៍ក៏អាចជាស្ថាប័ន និងសហគ្រាសវប្បធម៌ដែលជារបស់រដ្ឋ ឬឯកជន ព្រមទាំងសហគ្រាសក្នុងវិស័យមិនផ្លូវការ ដោយមិនភ្លេចរាប់ទាំងអង្គការដែលមានគោលបំណងមិនយកប្រាក់ចំណេញ ហើយដែលសន្យាចូលរួមក្នុងដំណើរការដូចគ្នានេះ។

## ២៥ តើប្រទេសកំពុងអភិវឌ្ឍទទួលបានអត្ថប្រយោជន៍អ្វីខ្លះ ?

ថ្វីត្បិតតែប្រទេសកំពុងអភិវឌ្ឍមានភាពសម្បូរបែបផ្នែកបង្កើតថ្មី និងផ្នែកវិញ្ញត្តិវប្បធម៌ក៏ពិតមែន ប៉ុន្តែវាមានភាពខុសប្លែកពីគ្នារវាងប្រទេសទាំងនោះ និងប្រទេសលូតលាស់ដែលមានលទ្ធភាពផលិត និងផ្សព្វផ្សាយវិញ្ញត្តិវប្បធម៌របស់ខ្លួន ជាហេតុធ្វើឲ្យលទ្ធភាពចូលរួមក្នុងសកម្មភាពផ្សេងៗនៅថ្នាក់អន្តរជាតិមានការថយចុះ។ ហេតុដូច្នេះហើយទើបមានបទបញ្ញត្តិជាច្រើននៃអនុសញ្ញាដែលផ្តោតទៅលើកិច្ចសហប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការដើម្បី អភិវឌ្ឍ សំដៅឆ្ពោះទៅរកប្រទេសកំពុងអភិវឌ្ឍ។ បទបញ្ញត្តិទាំងនោះអះអាងថាត្រូវពង្រឹងឧស្សាហកម្មវប្បធម៌ និងសមត្ថភាពស្ថាប័នព្រមទាំងការគ្រប់គ្រង ការផ្ទេរបច្ចេកវិទ្យា និងចំណេះធ្វើ និងការគាំពារហិរញ្ញប្បទានដោយរូបភាពផ្សេងៗគ្នា (មាត្រា១៤)។ គម្រោងខ្លះៗនៃកិច្ចសហប្រតិបត្តិការអាចនឹងទទួលការឧបត្ថម្ភពីមូលនិធិអន្តរជាតិដើម្បីភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ (មាត្រា១៨)។

## ២៦ តើអនុសញ្ញាគិតគូរដល់មនុស្សដែលស្ថិតនៅក្នុងចំណោមជនជាតិភាគតិច និងជនជាតិដើមឬទេ ?

ថ្វីត្បិតតែអនុសញ្ញាមិនបានគិតគូរជាពិសេសដល់វិញ្ញត្តិវប្បធម៌នៃជនជាតិភាគតិច និងអ្នកស្រុកដើមក្តី តែអត្ថបទបានទទួលស្គាល់ពីសារៈសំខាន់នៃវិញ្ញត្តិទាំងក្នុងភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។ ជាឧទាហរណ៍ បុព្វកថានៃអនុសញ្ញាបានរំលឹកពីសារសំខាន់នៃចំណេះដឹងបែបបុរាណ។ ជាពិសេសប្រព័ន្ធចំណេះដឹងនៃជនជាតិដើម ក្នុងនាមនៃប្រភពសម្បត្តិអរូបី និងការចូលរួមប្រកបដោយភាពវិជ្ជមានដល់ការអភិវឌ្ឍន៍ជានិរន្តរភាព។ ម្យ៉ាងទៀត អនុសញ្ញាអះអាងពីគោលការណ៍នៃភាពថ្លៃថ្នូរស្មើៗគ្នា និងការគោរពដល់វប្បធម៌ រួមទាំងវប្បធម៌នៃជនជាតិភាគតិច និងជនជាតិដើម (មាត្រា២.៣)។ លើសពីនោះទៀត អនុសញ្ញាបានអំពាវនាវដល់រដ្ឋភាគីឲ្យ "គិតគូរឲ្យបានត្រឹមត្រូវដល់លក្ខខណ្ឌនិងតម្រូវការពិសេស(...) នៃក្រុមមនុស្សផ្សេងៗក្នុងសង្គម រួមទាំងជនជាតិភាគតិច និងជនជាតិដើម ដើម្បីឲ្យរដ្ឋភាគីអាចបង្កើតផលិត ផ្សព្វផ្សាយ និងបែងចែកវិញ្ញត្តិវប្បធម៌របស់ពួកគេផ្ទាល់" (មាត្រា៧.១.ក) ក្នុងការទទួលសិទ្ធិ និងកាតព្វកិច្ចនៅថ្នាក់អន្តរជាតិ។

ពីព្រោះថាជនជាតិភាពតិច និងជនជាតិដើម សុទ្ធតែជាអ្នកមានចំណេះ ដែលមានតួនាទីសំខាន់ក្នុងភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដោយភាពចម្រុះផង និងដោយទស្សនៈចំពោះពិភពលោកដែលពួកគេបានផ្ទេរទៅអ្នកផ្សេងផង។ ក៏ប៉ុន្តែ វិញ្ញត្តិវប្បធម៌របស់ពួកគេច្រើនតែត្រូវគេធ្វើឲ្យធ្លាក់ចុះខ្សោយ។ បែបនេះ វិញ្ញត្តិវប្បធម៌គឺជាអាទិភាពនៃអនុសញ្ញា។

## ២៧ តើអនុសញ្ញាមានគិតដល់កម្មសិទ្ធិបញ្ញាដែរឬទេ ?

នៅថ្នាក់អន្តរជាតិ អនុសញ្ញាមិនគិតតែទៅលើកម្មសិទ្ធិបញ្ញា ដែលស្ថិតនៅក្រោមឱវាទនៃអាណត្តិរបស់អង្គការពិភពលោកផ្នែកកម្មសិទ្ធិបញ្ញាប៉ុណ្ណោះទេ ។ អង្គការយូណេស្កូបានធ្វើការពិគ្រោះមិនផ្លូវការជាមួយអង្គការនេះ ក្នុងក្របខណ្ឌនៃការរៀបចំលិខិតុបករណ៍នេះ។ ក៏ប៉ុន្តែ អនុសញ្ញារាប់បញ្ចូលនូវសារៈសំខាន់នៃសិទ្ធិរបស់កម្មសិទ្ធិបញ្ញា ក្នុងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។ នៅក្នុងកថាមុខរបស់ខ្លួន អនុសញ្ញាទទួលស្គាល់ ទី១ សារៈសំខាន់នៃសិទ្ធិទាំងនោះ ចំពោះអ្នកដែលចូលរួមក្នុងការបង្កើតគំនិតវប្បធម៌ថ្មី (វាក្យខណ្ឌ ១៧) និងទី២ ភាពចាំបាច់ក្នុងការធានាឲ្យបានសមស្របនូវការការពារ និងលើកស្ទួយចំណេះដឹងបុរាណ និងជាពិសេសប្រព័ន្ធចំណេះដឹងនៃជនជាតិដើម ក្នុងនាមជាប្រភពទ្រព្យសម្បត្តិអរូបី និងរូបី (វាក្យខណ្ឌ ៨)។

## ២៨ តើអនុសញ្ញាគិតគូរដល់ភាពផ្សេងៗគ្នានៃភាសាដែរឬទេ ?

ភាសាចូលរួមរួចជាស្រេចក្នុងភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។ ដើម្បីមូលហេតុនេះ តួនាទីចម្បងនៃភាពផ្សេងៗគ្នានៃភាសា ក្នុងការលើកស្ទួយភាពផ្សេងៗគ្នានៃវប្បធម៌ មានរំឭកនៅក្នុងកថាមុខ។ លើសពីនោះទៀត មាត្រា ៦.២.ខ ដែលលើកឡើងពីវិធានការដែលរដ្ឋភាគីនៃអនុសញ្ញាអាចចាត់ចែងធ្វើ ដើម្បីផ្តល់ឱកាសដល់សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មក្នុងស្រុកក្នុងការស្វែងរកតួនាទីខ្លួន នៅ

ក្នុងចំណោមសកម្មភាពទ្រព្យសម្បត្តិ និងសេវាកម្មដែលមានបម្រើជូននៅលើទឹកដីរបស់ខ្លួន ក៏មាននិយាយផងដែរពីការចាត់វិធានការទាក់ទងនឹងការប្រើប្រាស់ភាសា សម្រាប់សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មដែលបានចែងខាងលើនោះ។ មានន័យថារដ្ឋភាគី ចំពោះមុខបណ្តានយោបាយ និងវិធានការដែលរដ្ឋភាគីមានសិទ្ធិអនុវត្ត ដើម្បីសម្រួលដល់ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ក៏អាចសម្រួលដល់ភាពផ្សេងៗគ្នានៃភាសា សម្រាប់ដំណាក់ការបង្កើតថ្មី ផលិត ផ្សព្វផ្សាយ និងចែកចាយវិញ្ញត្តិវប្បធម៌ដែរ តាមរយៈសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្ម ដោយគោរពសេរីភាពមូលដ្ឋាន ព្រមទាំងគោរពគោលការណ៍ស្មើភាពគ្នា និងការបើកទូលាយចំពោះអនុសញ្ញានេះ (មាត្រា៩)។

## ២៩ តើអនុសញ្ញាកំហិតការផ្សព្វផ្សាយដោយសេរីនូវ គំនិត និងព័ត៌មានដែរឬទេ ? តើអនុសញ្ញាបញ្ជាក់ប្រាប់ពីមូលហេតុនៃការត្រួតពិនិត្យព័ត៌មានដែរឬទេ ?

ចាប់ពីកថាមុខតទៅ អនុសញ្ញាអះអាងជាថ្មីថា "សេរីភាពក្នុងការគិត បញ្ចេញមតិ និងទទួលបានព័ត៌មាន និងភាពផ្សេងៗគ្នានៃប្រព័ន្ធផ្សព្វផ្សាយ អាចជំរុញឲ្យមានការរីកសុសសាយនៃវិញ្ញត្តិវប្បធម៌នៅក្នុងសង្គម" (វាក្យខណ្ឌ១២)។ ម្យ៉ាងវិញទៀត គោលការណ៍កំណត់ទិសដំបូងលើកឡើងពីការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដូចដែលមានចែងដោយសេចក្តីប្រកាសជាសាកលនៃសិទ្ធិមនុស្ស (មាត្រា២.១)។ ដូច្នេះ អនុសញ្ញាអាចឃ្លាតចាកពីន័យដើម ក្នុងករណីដែលរដ្ឋនានាប្រព្រឹត្តបទល្មើសប្រឆាំងនឹងសិទ្ធិមនុស្ស ដូចមានទទួលស្គាល់ក្នុងលិខិតុបករណ៍គតិយុត្តិអន្តរជាតិ។

ថ្វីត្បិតតែអនុសញ្ញាអះអាងជាថ្មីពីអធិបតេយ្យភាពនៃរដ្ឋនានាក្នុងការអនុម័តនយោបាយ និងវិធានការ ដើម្បីសម្រួលដល់ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ក៏ពិតមែន តែអនុសញ្ញាក៏អះអាងដែរថានយោបាយ និងវិធានការទាំងនោះត្រូវតែគោរពតាមបទបញ្ញត្តិ គឺគោលបំណង គោលការណ៍ សិទ្ធិ និងកាតព្វកិច្ចដែលអនុសញ្ញាបានចែងឡើង។ អនុសញ្ញាមិនបង្កឲ្យមានការត្រួតពិនិត្យរឹងត្អឹងទេ តែផ្ទុយទៅវិញត្រូវបន្ថែមរបាំងពីលើបទបញ្ញត្តិដែលមានស្រាប់ ក្នុងការការពារសិទ្ធិមូលដ្ឋាន។

ការត្រួតពិនិត្យរឹងត្អឹងពីសំណាក់រដ្ឋាភិបាលមានហានិភ័យមិនជាក់លាក់យ៉ាងណា គោលការណ៍អធិប-តេយ្យនៃរដ្ឋភាគីក្នុងអនុសញ្ញាក៏ត្រូវគ្នានឹង "គោលការណ៍បើកទូលាយ និងតុល្យភាព" យ៉ាងនោះដែរ (មាត្រា២.៨)។ គោលការណ៍នេះគូសបញ្ជាក់ថារដ្ឋនានាដែលអនុម័តនយោបាយ និងវិធានការទាំងនោះ "ត្រូវធ្វើយ៉ាងណាលើកស្ទួយឲ្យបានសមស្របនូវការបើកទ្វារទៅ រកវប្បធម៌ដទៃក្នុងពិភពលោក..."។ ការបើកទូលាយនោះក៏ត្រូវគោរពទៅតាមសិទ្ធិ និងកាតព្វកិច្ច ព្រោះថាក្នុងនាមនៃមាត្រាទី៧ "រដ្ឋភាគីត្រូវខិតខំបង្កើតនៅលើទឹកដីរបស់ខ្លួននូវបរិយាកាសលើកទឹកចិត្តបុគ្គល និងក្រុមមនុស្សក្នុងសង្គម [...] ឲ្យទទួលបាននូវវិញ្ញត្តិវប្បធម៌ ដែលចេញពីទឹកដីរបស់ខ្លួន និងប្រទេសផ្សេងទៀតក្នុងពិភពលោក "។ ទីបញ្ចប់ រដ្ឋភាគីត្រូវធ្វើយ៉ាងណាចែករំលែកព័ត៌មាន និងជំរុញឲ្យមានតម្លាភាព ដោយផ្តល់ព័ត៌មានសមស្របស្តីពីការចាត់វិធានការដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ រាល់បួនឆ្នាំម្តង នៅក្នុងរបាយការណ៍ជូនអង្គការយូណេស្កូ (មាត្រា៩)។

# ៣០ តើអនុសញ្ញាអាចជះឥទ្ធិពលដល់របបពាណិជ្ជកម្មនៃរដ្ឋភាគីដែរឬទេ ?

អនុសញ្ញានិយាយពីភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ និងមានបំណងការពារ និងលើកស្ទួយជាពិសេសតាមរយៈនយោបាយ និងវិធានការផ្សេងៗ ហើយនិងតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ក៏ប៉ុន្តែអ្នកខ្លះចាត់ទុកថា នយោបាយ និងវិធានការ ដែលសំដៅជួយសម្រួលដល់សិល្បករ និងផលិតកម្មវប្បធម៌ក្នុងស្រុក អាចជះឥទ្ធិពលទៅលើរបបពាណិជ្ជកម្មនៃរដ្ឋភាគី។
ប៉ុន្តែនៅពេលដែលអនុសញ្ញាត្រូវបានចូលជាធរមានសម្រាប់រដ្ឋនានា និងអង្គការសេដ្ឋកិច្ចតំបន់ អនុសញ្ញានឹងមិនផ្លាស់ប្តូរ ហើយក៏មិនកែប្រែសិទ្ធិ និងកាតព្វកិច្ច ដែលរដ្ឋទាំងនោះបានបំពេញ ទៅតាមលិខិតុបករណ៍គតិយុត្តិផ្សេងៗទៀត រួមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ ទោះជាមានលក្ខណៈទ្វេភាគី តំបន់ ឬពហុភាគីក្តី។

នៅពេលបញ្ចប់មធ្យោបាយបទដ្ឋាននៃអង្គការយូណេស្កូផ្នែកវប្បធម៌បានសព្វគ្រប់ហើយ អនុសញ្ញាមិនត្រូវសើរើឡើងវិញពីភាពឯករាជ្យ និងស្វ័យភាពនៃច្បាប់ពាណិជ្ជកម្មអន្តរជាតិឡើយ។ ចំពោះចំណុចនេះ វាជាការសំខាន់ណាស់ក្នុងការបញ្ជាក់ថា ពាក្យថា "ការពារ" នៅក្នុងបរិបទនៃអង្គការយូណេស្កូ មានន័យថា ៖ ការអនុម័តវិធានការសំដៅការពារអភិរក្សនិងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌(មាត្រា៤.៧)។ ក្នុងន័យនេះហើយដែលគេប្រើពាក្យនេះក្នុងលិខិតុបករណ៍ជាច្រើននៃអង្គការយូណេស្កូ ក្នុងផ្នែកវប្បធម៌ ឧទាហរណ៍ដូចជាអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌពិភពលោក វប្បធម៌ និងធម្មជាតិ នៅឆ្នាំ១៩៧២, អនុសញ្ញាស្តីពីការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក នៅឆ្នាំ២០០១ និងអនុសញ្ញាស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី នៅឆ្នាំ២០០៣។ គេប្រើពាក្យថា "ការពារ" នេះភ្ជាប់ជាមួយនឹងពាក្យ "លើកស្ទួយ"។ ពាក្យនេះឆ្លុះបញ្ចាំង នៅក្នុងអនុសញ្ញានេះ ពីភាពចាំបាច់ក្នុងការធានារ៉ាប់រងជីវិត ឬការប្រឹងប្រែងរស់ ពីភាពផ្សេងៗនៃវិញ្ញត្តិវប្បធម៌ដែលមិនទទួលបាននូវការធានាក្នុងបរិបទបច្ចុប្បន្ននៃការពន្លឿនអភិក្រមសាកលភាវូបនីយកម្ម។